ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
NGO EDUCATION PARTNERSHIP

# ការទម្លាក់ថវិកាកម្មវិធី
# សម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍

## ករណីសិក្សាក្នុងខេត្តចំនួនប្រាំនៅប្រទេសកម្ពុជា
## ខែមិថុនា ឆ្នាំ២០១៥





ឧបត្ថម្ភថវិកាដោយៈ

UNESCO
United Nations
Educational, Scientific and
Cultural Organization

MISEREOR
IHR HILFSWERK

# ពាក្យបំព្រួញ និងអក្សរកាត់

| | | |
|---|---|---|
| CLC | : | មជ្ឈមណ្ឌលសិក្សាសហគមន៍ (ម.ស.ស) |
| DoE | : | ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក |
| DNFE | : | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| FGD | : | ការពិភាក្សាក្រុម |
| NEP | : | អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល |
| NFE | : | ការអប់រំក្រៅប្រព័ន្ធ |
| PoE | : | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត |
| STs | : | គ្រូជំនាញមុខរបរ |
| UNESCO | : | អង្គការយូណេស្កូ |

# សេចក្តីថ្លែងអំណរគុណ

អង្គការ NEP សូមថ្លែងអំណរគុណយ៉ាងស្មោះសរចំពោះលោកប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ មន្ត្រីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាស្រុក ប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ គ្រូជំនាញមុខរបរ និងប្រធានធនាគារខេត្តដែលបានចំណាយពេលវេលា ដ៏មានតម្លៃដើម្បីផ្តល់ព័ត៌មានដែលពាក់ព័ន្ធសម្រាប់ការស្រាវជ្រាវនេះ។

សូមថ្លែងអំណរគុណជាពិសេសចំពោះលោក **ចាន់ តុលា** អ្នកស្រាវជ្រាវដែលបានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយអង្គការ NEP ក្នុងការដឹកនាំការស្រាវជ្រាវនេះនៅមូលដ្ឋាន និងសរសេររបាយការណ៍ជាសេចក្តីព្រាងសម្រាប់អង្គការ NEP និងអង្គការយូណេស្កូ។ អង្គការ NEP វាយតម្លៃខ្ពស់ចំពោះក្រុមការងារអង្គការ NEP រួមមានអ្នកស្រី **អាង សុផា** មន្ត្រីសម្របសម្រួលការស្រាវជ្រាវ លោក **ឡាយ វុត្ថា** មន្ត្រីសម្របសម្រួលផ្នែកការងារអប់រំក្រៅប្រព័ន្ធ អ្នកស្រី **សុង គន្ធា** មន្ត្រីសម្របសម្រួលផ្នែកអប់រំ និងសេវាសមាជិក និងកញ្ញា **ឈុំ ស៊ីរ៉ុម** មន្ត្រីផ្នែកស្រាវជ្រាវដែលបានដឹកនាំការប្រមូលទិន្នន័យយ៉ាងសកម្មនៅក្នុងខេត្តគោលដៅនៃការស្រាវជ្រាវ។ បុគ្គលិករបស់អង្គការយូណេស្កូប្រចាំនៅភ្នំពេញ លោក **រស់ សុវាចា** មន្ត្រីសម្របសម្រួលផ្នែកកម្មវិធីអប់រំសម្រាប់ទាំងអស់គ្នា និងលោក **ឃិនសៀង សុមេធ** មន្ត្រីកម្មវិធីអប់រំថ្នាក់ជាតិ និង បុគ្គលិករបស់អង្គការ NEP លោក **ពេជ្រ និពន្ធ** មន្ត្រីសម្របសម្រួលផ្នែកយុទ្ធនាការនិងការតស៊ូមតិនិងលោក **ខូលីន អេនឌឺសិន** ទីប្រឹក្សាផ្នែកការតស៊ូមតិនិងទំនាក់ទំនងជាមួយម្ចាស់ជំនួយដែលបានចូលរួមផ្តល់ជាធាតុចូលចំពោះវិធីសាស្ត្រនិងឧបករណ៍សម្រាប់ប្រមូលទិន្នន័យព្រមទាំងការបណ្តុះបណ្តាលអំពីការប្រមូលទិន្ន័យ ។

អង្គការ NEP សូមសម្តែងនូវការដឹងគុណផងដែរចំពោះអ្នកប្រមូលទិន្ន័យទាំងអស់ដែលបានចូលរួមប្រមូលព័ត៌មានយ៉ាងសកម្មនៅមូលដ្ឋាន ហើយក៏សូមសម្តែងនូវអំណរគុណជាពិសេសចំពោះអង្គការ UNESCO និង MISEREOR សម្រាប់ការគាំទ្រហិរញ្ញវត្ថុដើម្បីធ្វើឲ្យការសិក្សានេះសម្រេចទៅបាន។

## មាតិកា

I. សេចក្ដីផ្ដើម ........ 6

II. គោលបំណងនៃការសិក្សា ........ 8

III. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ 9

IV. លទ្ធផលនៃការសិក្សា ........ 12

ការអង្កេតទៅលើបរិស្ថានរូបវន្តរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ........ 12

A: ការរៀបចំផែនការថវិកាកម្មវិធី ........ 14

តួនាទីរបស់អ្នកគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ........ 15

តួនាទីរបស់ការិយាល័យអប់រំស្រុក ........ Error! Bookmark not defined.

តួនាទីរបស់មន្ទីរអប់រំខេត្ត ........ Error! Bookmark not defined.

បញ្ហាក្នុងការរៀបចំផែនការថវិកា ........ Error! Bookmark not defined.

B: ការវិភាជថវិកា ........ 21

ការវិភាជថវិការបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធទៅឲ្យថ្នាក់ខេត្ត ........ Error! Bookmark not defined.

ការវិភាជថវិការបស់មន្ទីរអប់រំខេត្តទៅឲ្យការិយាល័យអប់រំស្រុក និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ........ Error! Bookmark not defined.

មូលហេតុនៃការវិភាជថវិកាសារជាថ្មី ........ Error! Bookmark not defined.

C: ការទម្លាក់ថវិកា ........ 25

ដំណើរការ និងឋានានុក្រមនៃការទម្លាក់ថវិកា ........ Error! Bookmark not defined.

ថវិកាដែលបានទម្លាក់ជាក់ស្ដែងជាមួយនឹងថវិកាដែលបានអនុម័ត ........ Error! Bookmark not defined.

ការផ្តល់សម្ភារៈជាមួយនឹងការផ្តល់ថវិកាជាសាច់ប្រាក់........Error! Bookmark not defined.
ភាពទាន់ពេលវេលា និងភាពញឹកញាប់នៃការទម្លាក់ថវិកា ...Error! Bookmark not defined.
ផលប៉ះពាល់នៃការទម្លាក់ថវិកាយឺតយ៉ាវ និងការបើកប្រាក់ខែយឺតយ៉ាវ .....Error! Bookmark not defined.
មូលហេតុនៃការពន្យាពេលទម្លាក់ថវិកា ...........................Error! Bookmark not defined.
ការពេញចិត្តរបស់ប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ចំពោះដំណើរការនៃការទម្លាក់ថវិកា និងសំណូមពរដើម្បីកែលម្អ ..................................................................... 38
V. សេចក្តីសន្និដ្ឋាន ..................................................................................... 40
VI. អនុសាសន៍ ............................................................................................ 43

# I. សេចក្តីផ្តើម

## មជ្ឈមណ្ឌលសិក្សាសហគមន៍ (ម.ស.ស)

មជ្ឈមណ្ឌលសិក្សាសហគមន៍(ម.ស.ស)គឺជាស្ថាប័នដែលត្រូវបានបង្កើតឡើងនៅក្នុងសហគមន៍ក្នុងគោលបំណងផ្តល់ការបណ្តុះបណ្តាលនិងការអប់រំ។ជាងនេះទៀតមជ្ឈមណ្ឌលសិក្សាសហគមន៍មានតួនាទីជាមជ្ឈមណ្ឌលព័ត៌មានសម្រាប់ប្រជាពលរដ្ឋនៅមូលដ្ឋានក្នុងការទទួលបាននូវព័ត៌មានផ្សេងៗអំពីការបណ្តុះបណ្តាលនិងសេវានៅមូលដ្ឋាន ។ មជ្ឈមណ្ឌលសិក្សាសហគមន៍ត្រូវបានបង្កើតឡើងដើម្បីឆ្លុះបញ្ចាំងពីតម្រូវការរបស់សហគមន៍និងដើម្បីផ្តល់សេវាអប់រំក្រៅប្រព័ន្ធ ។ មជ្ឈមណ្ឌលសិក្សាសហគមន៍មិនត្រឹមតែបានទទួលការជួយគាំទ្រពីក្រសួងអប់រំ យុវជននិងកីឡាប៉ុណ្ណោះទេប៉ុន្តែថែមទាំងបានទទួលការជួយគាំទ្រពីក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកិច្ចការនារី។

យោងតាមរបាយការណ៍សន្និបាទអប់រំឆ្នាំ២០១៤ មជ្ឈមណ្ឌលសិក្សាសហគមន៍នៅទូទាំងប្រទេសកម្ពុជាមានចំនួន ៣៤៧ ក្នុងនោះមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន ២៣ ត្រូវបានអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាល និងមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន ៣២៤ ទៀត ត្រូវបានអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា ។ មជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន ៣៣៧ ត្រូវបានគេរកឃើញថាមានដំណើរការនៅឆ្នាំ ២០១៤ ដោយមានថ្នាក់បណ្តុះបណ្តាលជំនាញទាំងអស់ចំនួន ៦៧១ថ្នាក់។ សិស្សចុះឈ្មោះចូលរៀនមានចំនួនសរុប ៩៩១៦ (ស្រី៦៣%) និង ៨៥.៩%នៃសិស្សសរុបត្រូវបានរាយការណ៍ថាបានបញ្ចប់កម្មវិធី ។

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ការវិភាជថវិកាប្រចាំឆ្នាំសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍ឆ្នាំ២០១៤ ក្នុងឯកសារមួយដែលមានចំណងជើងថា "**ការអនុវត្តថវិកាកម្មវិធី និងការវិភាជថវិកាសម្រាប់កម្មវិធីអប់រំក្រៅប្រព័ន្ធ**" ដែលចេញផ្សាយក្នុងខែ ធ្នូ ឆ្នាំ២០១៣។ នេះបានបង្ហាញពីថវិកាអនុវត្តថ្នាក់ជាតិសរុបមានចំនួន ២,៨៥៩ លានរៀល ប្រហែលជា ៧១៤,៨២៥ ដុល្លាអាមេរិក។ ក្នុងនោះ ថវិកាចំនួន ៩៥% (ឬ ២៧១៩លានរៀល) ត្រូវបានរកឃើញថាជាចំណាយនៅថ្នាក់ខេត្តក្នុងការផ្តល់ជាមូលនិធិផ្ទាល់ចំពោះមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលមានស្រាប់ ដែលមានចំនួនប្រមាណជា ៨.៤ លានរៀល ឬ ២០៩៨ ដុល្លាអាមេរិក សម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍នីមួយៗ ប្រសិនបើថវិកាត្រូវបានបែងចែកស្មើៗគ្នាសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន២៣៤។ ថវិកាទាំងនេះសម្រាប់ចាយវាយលើសម្ភារ បរិក្ខា និងសម្រាប់ប្រាក់បៀវត្សគ្រូជំនាញមុខរបរ ។ ៥% នៃថវិកាដែលត្រូវបានវិភាជទៅថ្នាក់ជាតិ រួមបញ្ចូលទាំងការចំណាយលើការពង្រឹងសមត្ថភាពរបស់ប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ (ម.ស.ស)នៅថ្នាក់ក្រោមជាតិ។

អង្គការយូណេស្កូបាននិងកំពុងគាំទ្រអក្ខរកម្មនិងវិស័យអប់រំក្រៅប្រព័ន្ធក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ ១៩៩៤។ កម្មវិធីអភិវឌ្ឍសមត្ថភាពលើការអប់រំសម្រាប់ទាំងអស់គ្នារបស់អង្គការយូណេស្កូបានចាប់ផ្តើមឡើង

តាំងពីឆ្នាំ២០០៣ និងឧបត្ថម្ភថវិកាដោយ៦ប្រទេស រួមមាន ប្រទេសដាណឺម៉ាក ប្រទេសហ្វាំងឡង់ ប្រទេសអ៊ីតាលី ប្រទេសន័រវេស ប្រទេសស៊ុយអែត និងប្រទេសស្វីស។ ប្រទេសកម្ពុជាត្រូវបានជ្រើសរើសជាប្រទេសអាទិភាពមួយក្នុងចំណោម ២០ប្រទេស ដើម្បីអនុវត្តកម្មវិធីនេះ។ ក្នុងឆ្នាំ២០១០ ក្រោមកម្មវិធីអភិវឌ្ឍន៍សមត្ថភាពលើការអប់រំសម្រាប់ទាំងអស់គ្នា នាយកដ្ឋានអប់រំក្រៅប្រព័ន្ធរបស់ក្រសួងអប់រំ យុវជននិង កីឡា បានធ្វើការវាយតម្លៃមួយលើសមត្ថភាពក្នុងស្ថាប័ន ហើយការិយាល័យអង្គការយូណេស្កូនៅទីក្រុងភ្នំពេញបានធ្វើការវាយតម្លៃមួយលើសមត្ថភាពក្រៅស្ថាប័ន។ ការវាយតម្លៃនេះផ្តល់ ការពិនិត្យដ៏ស៊ីជម្រៅលើវិស័យអប់រំក្រៅប្រព័ន្ធដែលបង្ហាញពីសមត្ថភាពមានកម្រិតរបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធលើផ្នែក៥ ដូចជា ភាពជាអ្នកដឹកនាំ សុខដុមនីយកម្ម និងភាពជាដៃគូ សមត្ថភាពគ្រប់គ្រងស្ថាប័ន គុណភាព និងសមភាព និងការប្រើប្រាស់ចំណេះដឹង។ ដោយផ្អែកទៅលើលទ្ធផលនៃការវាយតម្លៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាពលើការអប់រំសម្រាប់ទាំងអស់គ្នា (CapEFA) របស់ការិយាល័យអង្គការយូណេស្កូនៅទីក្រុងភ្នំពេញបានជួយគាំទ្រនាយកដ្ឋានអប់រំក្រៅប្រព័ន្ធក្នុងការពង្រឹងការងារអក្ខរកម្ម និងការអប់រំក្រៅប្រព័ន្ធតាមរយៈការរៀបចំផែនការតាមវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា។ កម្មវិធីអភិវឌ្ឍន៍សមត្ថភាពលើការអប់រំសម្រាប់ទាំងអស់គ្នានេះត្រូវបានរៀបរៀងឡើងស្របតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ២០០៩-២០១៣ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ២០១៤-២០១៨ និងផែនការប្រតិបត្តិការប្រចាំឆ្នាំ(AOP) របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលអង្គការយូណេស្កូ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀតបានកំពុងផ្តល់ជំនួយបច្ចេកទេសដល់ក្រសួងលើវិស័យអប់រំក្រៅប្រព័ន្ធ។

អង្គការយូណេស្កូបានគាំទ្រក្រសួងអប់រំ យុវជន និងកីឡា ដើម្បីកែសម្រួលសៀវភៅបណ្តុះបណ្តាលផ្នែកគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍។ ដើម្បីផ្តល់នូវសេវាអប់រំពេញមួយជីវិត និងការអប់រំក្រៅប្រព័ន្ធ សៀវភៅបណ្តុះបណ្តាលនេះមានបំណងចង់ពង្រឹងគណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ គណៈកម្មាធិការទ្រទ្រង់មជ្ឈមណ្ឌលសិក្សាសហគមន៍ ការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត។ បណ្តាញរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ក៏ផ្តល់ថ្នាក់អក្ខរកម្មសម្រាប់សិស្សដែលបោះបង់ការសិក្សានៅបឋមសិក្សា អនក្ខរជន និងអក្ខរជនថ្មីៗ ។ គោលនយោបាយថ្នាក់ជាតិទទួលស្គាល់ថា តួនាទីរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ត្រូវតែធ្វើឱ្យមានភាពខុសគ្នាបន្តិចម្តងៗដើម្បីឆ្លើយតបនឹងតម្រូវការជាច្រើនរបស់សហគមន៍។

## កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

រាជរដ្ឋាភិបាលកម្ពុជាបានកំពុងធ្វើឱ្យមានការរីកចម្រើនលើគោលនយោបាយការចំណាយសារធារណៈក្រោយពេលចាប់អនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ (PFMRP) នៅឆ្នាំ២០១៤ (Work Bank, 2011)។ ជាឧទាហរណ៍ ការលុបបំបាត់ជាស្ថាពរនូវការបង់ប្រាក់ចាប់តាំងពីឆ្នាំ២០០៧ និងការកែលម្អលើការទម្លាក់ថវិកាចុងត្រីមាស (MEF, 2009)។ អត្រានៃការទម្លាក់ថវិកាបានកើនឡើងយ៉ាងខ្លាំង (ពី៦០% ទៅ៩០%)បើយោងតាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កម្រែទម្រង់របស់រាជរដ្ឋាភិបាលរួមមានការពង្រឹងដំណើរការបង្កើត និងប្រតិបត្តការថវិកាការកែលម្អលើការរកប្រាក់ចំណូល និងការប៉ាន់ស្មានប្រាក់ចំណូលការគ្រប់គ្រងសាច់ប្រាក់ឱ្យបានល្អប្រសើរជាងមុន និងការដាក់ឱ្យប្រើដំណើរការពិនិត្យឡើងវិញថវិកាពាក់កណ្តាលឆ្នាំ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានកំពុងពង្រឹង និងពង្រីកការប្រើប្រាស់ធនាគារពាណិជ្ជសម្រាប់ការផ្ទេរសាច់ប្រាក់ ឧទាហរណ៍ គឺប្រាក់បៀវត្សរបស់គ្រូបង្រៀនក្នុងស្ថាប័នអប់រំរដ្ឋ។ បើយោងតាមការវាយតម្លៃនៃការដាក់បញ្ចូលអ្នកជានា និងការពិនិត្យឡើងវិញនូវការចំណាយសាធារណៈ ការផ្លាស់ប្តូរអង្គភាពគ្រប់គ្រងសាច់ប្រាក់ឱ្យទៅកាន់អគ្គនាយកដ្ឋានរតនាគារជាតិបានជួយពង្រឹងការគ្រប់គ្រងសាច់ប្រាក់ដើម្បីធានាឱ្យមានភាពអាចទុកចិត្តបាន និងភាពដែលអាចរកបាននៃធនធានថវិកាបានល្អប្រសើរជាងមុន (World Bank, 2011)។ ទោះជាយ៉ាងណាក្តីកំណែទម្រង់ត្រូវបានរកឃើញថាបានរាំងស្ទះដោយសារកង្វះជំនាញ បច្ចេកទេសនិងសមត្ថភាពទន់ខ្សោយដែលធ្វើឱ្យមានតម្រូវការពង្រឹងសមត្ថភាពជាបន្តបន្ទាប់។ ជាឧទាហរណ៍ ការប្រតិបត្តិថវិកានៅតែជួបការពន្យាពេល និងការតម្លាក់ថវិកាដែលមិនអាចប្រមាណទុកមុនបាន។ ការពន្យារការទម្លាក់ថវិកាធ្វើឱ្យប៉ះពាល់សឹងតែគ្រប់វិស័យរួមបញ្ចូលទាំងវិស័យអប់រំក្រៅប្រព័ន្ធ។

### គោលការណ៍ណែនាំលើការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍

គោលការណ៍ណែនាំលើមជ្ឈមណ្ឌលសិក្សាសហគមន៍ គឺជាសៀវភៅមគ្គុទេសន៍ស្តីអំពីការគ្រប់គ្រង និងការអនុវត្តន៍មជ្ឈមណ្ឌលសិក្សាសហគមន៍ដែលត្រូវបានបោះពុម្ពផ្សាយចុងក្រោយក្នុងឆ្នាំ២០១៤ សម្រាប់ការិយាល័យថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់អនុវត្តតាម។គោលការណ៍ណែនាំនេះរួមមាន សេចក្តីលម្អិតលើការគ្រប់គ្រងនិងការទម្លាក់ថវិកា។ ដូចមានចែងក្នុងគោលការណ៍ណែនាំមន្ទីរអប់រំខេត្តត្រូវតែសម្រួល និងទម្លាក់ថវិកា ទៅឱ្យការិយាល័យអប់រំស្រុក អាស្រ័យទៅលើចំនួនជាក់លាក់របស់មជ្ឈមណ្ឌលសិក្សាសហគមន៍ដែលដំណើរការនៅតាមស្រុកនិមួយៗ។ រួចមន្ទីរអប់រំខេត្តត្រូវតែផ្ទៀងផ្ទាត់និងតម្លាក់ថវិកាទៅឱ្យមជ្ឈមណ្ឌលសិក្សាសហគមន៍និមួយៗនៅតាមស្រុករបស់គេ (CLC guidelines, 2014)។

ដំណើរការរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ត្រូវបានមើលការខុសត្រូវដោយប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍នៅតាមសហគមន៍។ សម្រាប់ករណីភាគច្រើនប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍គឺជាមន្ត្រីស៊ីវិលដែលមានមុខតំណែងស្រាប់ទៅហើយដែលជានិច្ចកាលជានាយកសាលារៀនម្នាក់។ មន្ត្រីស៊ីវិលទាំងនេះត្រូវបានគោរាយការណ៍ថា មិនបានទទួលប្រាក់ខែបន្ថែមលើតួនាទីនេះទេ។

## II. គោលបំណងរួមនៃការសិក្សា

ក្នុងដំណើរការប្រតិបត្តិការរបស់វា មជ្ឈមណ្ឌលសិក្សាសហគមន៍អាចជួបប្រទះនូវបញ្ហាប្រឈមនានាដែលបង្អាក់ស្ថាប័នទាំងនេះពីការផ្តល់សេវាដែលមានគុណភាពសម្រាប់សហគមន៍។ បញ្ហាប្រឈមមួយ

ក្នុងចំណោមបញ្ហាប្រឈមជាច្រើនគឺការទម្លាក់ថវិកាមិនល្អ។ ទម្លាប់នៃដំណើរការតម្លាក់ថវិកា និងការរំពឹងជាច្រើនមកលើគោលការណ៍ណែនាំអំពីមជ្ឈមណ្ឌលសិក្សាសហគមន៍គឺប្រហែលជាមិនដូចគ្នា។ បើទោះជាមានគោលការណ៍ណែនាំអំពីភាពជាអ្នកគ្រប់គ្រង និងការគ្រប់គ្រងនៃមជ្ឈមណ្ឌលសិក្សាសហគមន៍ វានៅតែជាកង្វល់ដែលថាបញ្ហាប្រឈមនៅតែមាន។ ដូច្នេះហើយ វាជាការសំខាន់ដែលត្រូវតែស៊ើបអង្កេតការទម្លាក់ថវិកាទៅកាន់មជ្ឈមណ្ឌលសិក្សាសហគមន៍ និងវាអាចនឹងផ្តល់ជាអនុសាសន៍បន្ថែមទៀតសម្រាប់សកម្មភាពនាពេលខាងមុខ។

ការសិក្សាមានបំណងស៊ើបអង្កេតលើដំណើរការនៃការទម្លាក់ថវិកាសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍ដែលមើលការខុសត្រូវដោយនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ដើម្បីរកឱ្យឃើញនូវរឿងរ៉ាវនានា បញ្ហាប្រឈម និងផ្តល់ជាអនុសាសន៍។ ដើម្បីឆ្លើយតបនឹងគោលបំណងរួម ការសិក្សានេះប្រើសំណួរគោលនៃការស្រាវជ្រាវចំនួន៣៖

1. តើអ្វីខ្លះជាទម្លាប់នៃការរៀបចំថវិកា និងការទម្លាក់ថវិកាសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍?

2. តើអ្វីខ្លះជាបញ្ហាដែលមជ្ឈមណ្ឌលសិក្សាសហគមន៍/នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ/មន្ទីរអប់រំខេត្តជួបប្រទះនៅជុំវិញដំណើរការទម្លាក់ថវិកា និងថាតើបញ្ហាទាំងនេះជះឥទ្ធិពលដល់មជ្ឈមណ្ឌលសិក្សាសហគមន៍យ៉ាងដូម្តេច?

3. តើអ្វីដែលអ្នកតំណាងឱ្យមជ្ឈមណ្ឌលសិក្សាសហគមន៍/ការិយាល័យអប់រំ/មន្ទីរអប់រំខេត្ត/នាយកដ្ឋានអប់រំក្រៅប្រព័ន្ធគិតថាគួរតែត្រូវផ្លាស់ប្តូរឬគួរតែត្រូវធ្វើដើម្បីធ្វើឱ្យការទម្លាក់ថវិកាកាន់តែមានប្រសិទ្ធិភាព?

## III. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះពាក់ព័ន្ធនឹងការរកឱ្យឃើញនូវរឿងរ៉ាវ ដែលលេចឡើងក្នុងការអនុវត្តកម្មវិធីមួយ។ ដូច្នេះហើយវិធីសាស្ត្រសិក្សាបែបគុណភាពត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ។ ទិន្ន័យដែលប្រមូលបានត្រូវបានវិភាគដោយផ្អែកលើប្រធានបទដែលលេចឡើង និងរៀបចំប្រធានបទតាមផ្នែកផ្សេងៗគ្នា។ ដើម្បីទទួលបាននូវទិន្ន័យដែលអាចឆ្លើយតបទៅនឹងសំណួរគោលនៃការស្រាវជ្រាវ ឧបករណ៍នៃការស្រាវជ្រាវផ្សេងៗគ្នាត្រូវបានបង្កើតឡើង និងធ្វើការសាកល្បង។ ឧបករណ៍ស្រាវជ្រាវសម្រាប់សម្ភាសន៍ដែលគ្រោងទុកមុន និងការពិភាក្សាក្រុមត្រូវបានបង្កើតឡើង និងប្រើក្នុងដំណើរការប្រមូលទិន្នន័យ។ ឧបករណ៍ស្រាវជ្រាវមានច្រើនបែបអាស្រ័យទៅលើប្រភេទនៃអ្នកចូលរួមឆ្លើយ។

ទិន្នន័យត្រូវបានប្រមូលពីខេត្តចំនួន៥ដែលតាងអោយតំបន់ភូមិសាស្ត្រផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា ដូចជាតំបន់ព្រំដែន តំបន់ទំនាប និងតំបន់ដែលរស់នៅដោយជនជាតិដើមភាគតិច ដោយយកចិត្តទុក

ដាក់លើខេត្តដែលមានអត្រាប្រាក់ចំណូលប្រជាជនមធ្យម និងទាប។ នៅក្នុងរបាយការណ៍នេះ ខេត្តទាំងនេះនឹងត្រូវជម្រួសដោយលេខដើម្បីរក្សាភាពសម្ងាត់របស់អ្នកចូលរួមឆ្លើយ។




*រូបភាព ១៖ ផែនទីនៃតំបន់ក្នុងការសិក្សានេះ*

## ការជ្រើសរើសសំណាក

លើកលែងតែខេត្តសៀមរាប ដែលមានមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួនសរុបតែ៣ នៅក្នុងខេត្តនីមួយៗមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន៥ ត្រូវបានជ្រើសរើសដោយក្រុមអ្នកស្រាវជ្រាវមកពីអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលនិងអ្នកស្រាវជ្រាវមកពីមជ្ឈមណ្ឌលសិក្សាសហគមន៍ទាំងអស់នៅក្នុងខេត្តនីមួយៗ។ នេះជាការជ្រើសរើសដោយមានគោលបំណងជាក់លាក់ដើម្បីធ្វើឱ្យប្រាកដថាការសិក្សាបានបញ្ចូលមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលមានទីតាំងនៅឆ្ងាយនិងនៅជិតក្រុង។ បុគ្គលដែលផ្តល់ព័ត៌មានចម្បងក្នុងការសិក្សានេះរួមមានដូចតារាងខាងក្រោមនេះ ។ ប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ជាច្រើនត្រូវបានអញ្ជើញឱ្យចូលរួមក្នុងការសិក្សានៅឯមជ្ឈមណ្ឌលសិក្សាសហគមន៍នីមួយៗបន្ទាប់មកធ្វើការពិភាក្សាក្រុមជាមួយគ្រូមុខជំនាញរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍នៅឯមជ្ឈមណ្ឌល ។ ក្នុងខេត្តនីមួយៗអ្នកប្រមូលទិន្នន័យ សម្ភាសន៍ប្រធានមន្ទីរអប់រំខេត្តបុគ្គលិកដែលទទួលខុសត្រូវមកពីការិយាល័យអប់រំស្រុកនិងទេសាភិបាលប្រចាំខេត្តម្នាក់។ ការសិក្សាក៏រៀបចំការប្រមូលទិន្នន័យនៅថ្នាក់ជាតិដែរ គឺពីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធនិងកម្រងឯកសារនៅថ្នាក់ជាតិ ។ ដើម្បីរក្សានូវការសម្ងាត់ឈ្មោះខេត្តក្នុងការសិក្សានេះត្រូវបានប្តូរការហៅទៅជាខេត្តលេខ១ខេត្តលេខ២ ខេត្តលេខ៣

ខេត្តលេខ៤ និងខេត្តលេខ៥។ ឈ្មោះស្រុក និងសម្ភាសជាមួយ ប្រធាន មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬជាមួយគណនេយ្យករ និងការពិភាក្សាក្រុម ក៏ត្រូវបានបង់លេខតាមខេត្ត ឧទាហរណ៍ ការិយាល័យអប់រំស្រុក ១.១ មជ្ឈមណ្ឌលសិក្សាសហគមន៍ ២.៣។

តារាងនេះបង្ហាញពីសំណាកដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ ដោយរួមបញ្ចូលទាំងឧបករណ៍ស្រាវជ្រាវ និងចំនួនសរុបនៃអ្នកចូលរួមក្នុងការសិក្សា។

| សកម្មភាពស្រាវជ្រាវ | ព្រះវិហារ | រតនគិរី | បន្ទាយមានជ័យ | សៀមរាម | កណ្តាល | ចំនួនអ្នកចូលរួម |
|---|---|---|---|---|---|---|
| ក្រុមពិភាក្សាជាមួយគ្រូជំនាញមុខរបរ | 2 | 3 | 2 | 1 | 2 | ការពិភាក្សា ១០ សរុបគ្រូ ៣៤ នាក់ |
| គណនេយ្យករ/អ្នកគ្រប់គ្រងរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ | 4 | 4 | 5 | 3 | 5 | គណនេយ្យករ/អ្នកគ្រប់គ្រង ចំនួន២១នាក់ |
| មន្ទីរអប់រំខេត្ត | 1 | 1 | 1 | 1 | 1 | មន្ទីរអប់រំខេត្ត ចំនួន៥នាក់ |
| ការិយាល័យអប់រំស្រុក | 2 | 3 | 2 | 2 | 2 | ការិយាល័យអប់រំស្រុកចំនួន ១១នាក់ |
| រតនាគារខេត្ត | | 1 | 1 | | 1 | រតនាគារខេត្ត ចំនួន៣នាក់ |
| **ចំនួនសរុបអ្នកចូលរួម** | | | | | | **៧៤នាក់** |

តារាង ១៖ ទំហំសំណាក

## ការប្រមូលទិន្នន័យ ការបណ្តុះបណ្តាល និងការសាកល្បងឧបករណ៍

ការសិក្សានេះប្រើប្រាស់អ្នកប្រមូលទិន្នន័យចំនួន១០នាក់ ដោយ២នាក់សម្រាប់ប្រមូលទិន្នន័យនៅខេត្តមួយ។ ការប្រមូលទិន្នន័យធ្វើឡើងពីថ្ងៃទី១៨ ដល់ទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៤។ ដើម្បីធានាឱ្យមានការ

ប្រមូលទិន្ន័យដែលមានគុណភាព  អ្នកប្រមូលទិន្ន័យដែលត្រូវបានជ្រើសរើសទាំងអស់ត្រូវតែចូលរួមការបណ្តុះបណ្តាលការប្រមូលទិន្ន័យរយៈពេល៣ថ្ងៃ (២-៣ វិច្ឆិកា) ដែលសម្របសម្រួលដោយក្រុមស្រាវជ្រាវមកពីអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល  ក្រុមមកពីអង្គការយូណេស្កូនិងអ្នកប្រឹក្សាមកពីអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ។ ឧបករណ៍ស្រាវជ្រាវត្រូវបានប្រើសាកល្បងនៅខេត្តកណ្តាល ។ ការប្រជុំផ្តល់ព័ត៌មានត្រឡប់ត្រូវបានរៀបចំនៅថ្ងៃដដែលដើម្បីកែសម្រួលឧបករណ៍ ស្រាវជ្រាវនិងដើម្បីផ្តល់ព័ត៌មានត្រឡប់ទៅក្រុមអ្នកប្រមូលទិន្នន័យវិញដើម្បីកែលម្អវិធីសម្ភាសន៍និងការកត់ត្រារបស់ ពួកគេវិញ។

### ក្រមសីលធម៌នៃការស្រាវជ្រាវ

ដើម្បីធានាបានភាពសម្ងាត់នៃអ្នកចូលរួមការស្រាវជ្រាវនេះ  បានប្រើសញ្ញាដើម្បីតំណាងឱ្យឈ្មោះខេត្ត ស្រុក មជ្ឈមណ្ឌលសិក្សាសហគមន៍ និងគ្រូបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ។ បន្ថែមពីនេះទៅទៀតអ្នកចូលរួមឆ្លើយម្នាក់ៗត្រូវបានសំណូមពរអោយស្តាប់អ្នកប្រមូល ទិន្នន័យអានខ្លឹមសារនៃលិខិតយល់ព្រមនិងយល់ព្រមផ្តល់ព័ត៌មានមុនពេលការសម្ភាសន៍ចាប់ផ្តើម។  ពួកគេក៏ត្រូវបានជម្រាបពីគោលបំណងនៃការសិក្សា ការរក្សាការសម្ងាត់ និងសិទ្ធិរបស់ពួកគេក្នុងការមិនប្រាប់នូវព័ត៌មានណាមួយ។

### ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សានេះមានបំណងធ្វើបទសម្ភាសន៍នៅមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន៥នៅខេត្តនីមួយៗ។ ការសិក្សាមានបំណងសម្ភាសន៍មជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន២៥  ប៉ុន្តែមជ្ឈមណ្ឌលសិក្សាសហគមន៍តែ ២១ប៉ុណ្ណោះ ដែលអនុញ្ញាតផ្តល់ការសម្ភាសន៍ ចំណែក ៤ ផ្សេងទៀតមិនអាចផ្តល់សម្ភាសន៍បានដោយសារប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍មិនទំនេរ  ហើយភូមិមិនអាចទៅដល់ដោយសារតែផ្លូវមានស្ថានភាពពិបាកខ្លាំង។

## IV. លទ្ធផលការសិក្សា

ដំបូងបង្ហស់នៃផ្នែកនេះរៀបរាប់ពីលទ្ធផលនៃការអង្កេតទូទៅ  បន្ទាប់មកគឺការពិពណ៌នាអំពីលទ្ធផលជាក់លាក់ដែលទាក់ទងទៅនឹងការតម្លាក់ថវិកា។

### ការអង្កេតទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍

ការធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលសិក្សាសហគមន៍ក្នុងខេត្តទាំង៥នេះត្រូវបានរកឃើញថាអគារនិងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗមានភាពខ្វះខាត  ចំណែកនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍ខ្លះមានភាពខ្វះខាតយ៉ាងខ្លាំង។  គ្រឿងឧបករណ៍  និងបរិក្ខាផ្សេងៗត្រូវបានរកឃើញថាមិនដំណើរការនៅតាម

មជ្ឈមណ្ឌលសិក្សាសហគមន៍មួយចំនួន។ បើទោះជាការវាយតម្លៃទៅលើបរិស្ថានជុំវិញការសិក្សាមិនមែនជាគោលបំណងនៃការសិក្សានេះក៏ដោយក៏វាជាបរិបទមួយដ៏សំខាន់សម្រាប់ការស្វែងយល់អំពីប្រតិបត្តិការរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍(ម.ស.ស)។

ក្នុងកំឡុងពេលទស្សនកិច្ចនៅមជ្ឈមណ្ឌលសិក្សាសហគមន៍ ការអង្កេតមើលបរិស្ថានរូបវន្តនៅមជ្ឈមណ្ឌលសិក្សាសហគមន៍ត្រូវបានកត់ត្រាទុកដោយស្វ័យប្រវត្តដោយអ្នកប្រមូលទិន្នន័យនីមួយៗ។ គួរឱ្យកត់សម្គាល់ផងដែរថាទស្សនកិច្ចនិងការអង្កេតនៅឯមជ្ឈមណ្ឌលសិក្សាសហគមន៍ធ្វើឡើងនៅចុងខែវិច្ឆិកានៅពេលដែលមជ្ឈមណ្ឌលសិក្សាសហគមន៍ជាច្រើនបានបញ្ចប់ថ្នាក់សម្រាប់ឆ្នាំសិក្សានេះ។ កំណត់ត្រានៃការអង្កេតលេចចេញជាលទ្ធផលទូទៅខ្លះៗ ដូចខាងក្រោមនេះ។

**ស្ថានភាពបន្ទប់សិក្សា៖** មជ្ឈមណ្ឌលសិក្សាសហគមន៍ភាគច្រើនមានតុកៅអីសម្រាប់អ្នកសិក្សា។ ប៉ុន្តែគ្រឿងបរិក្ខារ ហាក់មិនបានរៀបចំទុកដាក់និងសម្អាតបានល្អទេ។ ប្រហែលជា៥០%នៃមជ្ឈមណ្ឌលសិក្សាសហគមន៍មិនមានស្ថានភាពដូចជាបន្ទប់សិក្សាឡើយ។ ឧទាហរណ៍ នៅក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍១.៤ មានតែតុចាស់ពីរឬបីដែលមានធូលីក្រាស់ៗ។ មជ្ឈមណ្ឌលសិក្សាសហគមន៍នេះមើលទៅដូចត្រូវបានគេបោះបង់ចោលឈប់ប្រើប្រាស់។ មានភាពខុសគ្នាជាមួយមជ្ឈមណ្ឌលសិក្សាសហគមន៍នៅខេត្តលេខ៥ដែលមជ្ឈមណ្ឌលសិក្សាសហគមន៍ទាំងអស់ត្រូវបានមើលឃើញថាមានសភាពរៀបចំទុកដាក់មានរបៀបរៀបរយល្អរួមមានតុកៅអី និងក្តារខៀនស្អាតៗគ្មានធូលី។

**សម្ភារៈ(ជាពិសេសគ្រឿងម៉ាស៊ីន)៖** មជ្ឈមណ្ឌលសិក្សាសហគមន៍ក្នុងខេត្តទាំង៥ក្នុងការសិក្សានេះសុទ្ធតែមានឧបករណ៍និងសម្ភារៈបង្រៀនខ្វះខាតឬបែកបាក់។ ឧទាហរណ៍ មានម៉ាស៊ីនដេរជាមធ្យមចំនួន១០នៅតាមមជ្ឈមណ្ឌលសហគមន៍នីមួយៗ ប៉ុន្តែមានតែម៉ាស៊ីនពីរ ឬបីប៉ុណ្ណោះដែលស្ថិតក្នុងសភាពល្អ។ នៅឯមជ្ឈមណ្ឌលសិក្សាសហគមន៍១.១ និងមជ្ឈមណ្ឌលសិក្សាសហគមន៍១.២ គ្មានម៉ាស៊ីនដេរណាមួយដែលដំណើរការទេ ។ ដូចគ្នានេះដែរមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលផ្តល់ថ្នាក់បង្រៀនកាត់សក់ មិនមានឧបករណ៍គ្រប់គ្រាន់ទេ (កន្ត្រៃ កៅអីអង្គុយកាត់សក់ ជាដើម) សម្រាប់សិស្សអនុវត្តនោះទេ។ ឧទាហរណ៍ មជ្ឈមណ្ឌលសិក្សាសហគមន៍មួយចំនួនក្នុងខេត្តលេខ១ មានកៅអីអង្គុយកាត់សក់ដែលបែកបាក់ និងមិនអាចប្រើប្រាស់បាន។

**គ្រូនិងសិស្សជំនាញមុខរបរ៖** ម.ស.សភាគច្រើនបានបញ្ចប់ថ្នាក់សិក្សាមុនពេលដំណើរទស្សនកិច្ចបានចាប់ផ្តើម។ ដូច្នោះហើយវត្តមានសិស្សជាទូទៅមានចំនួនតិច។ ទោះជាយ៉ាងណាក៏ដោយ ក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍៣.៤ មានសិស្សចំនួន២៥នាក់ និងគ្រូជំនាះមុខរបរ (ជាងកាត់សក់) ម្នាក់មានវត្តមាននៅឯមជ្ឈមណ្ឌលសិក្សាសហគមន៍ ជាមួយនឹងគ្រូតន្ត្រីម្នាក់និងសិស្ស៤នាក់ផ្សេងទៀត។ នៅមជ្ឈមណ្ឌលសិក្សាសហគមន៍៥.៣ មានសិស្សចំរុះក្រុមគ្នា ក្នុងនោះមានគ្រូជំនាញមុខរបរ៣នាក់ សិស្សរៀនជំនាញសំអាង ១៤នាក់ សិស្សរៀនជំនាញកាត់សក់១៥នាក់ និង សិស្សរៀនជំនាញកាត់ដេរចំនួន១១នាក់។

តារាងខាងក្រោមបង្ហាញពីចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលបានអង្កេត ហើយភាគច្រើននៃមជ្ឈមណ្ឌលសិក្សាសហគមន៍(ម.ស.ស)ទាំងនោះបានបញ្ចប់ថ្នាក់សិក្សា។ ដូច្នេះហើយសកម្មភាពរៀន និងបង្រៀនមិនសូវមាន នៅពេលមានទស្សនកិច្ច។




*តារាង២៖ ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍(ម.ស.ស)ដែលបានបញ្ចប់ និងបន្តដំណើរការ*

ការអង្កេតបន្ទប់សិក្សាសម្ភារៈគ្រូជំនាញមុខរបរនិងសិស្សរួមចំណែកក្នុងការស្វែងយល់អំពីបញ្ហាថវិកាដែលនឹងរៀបរាប់ពេលក្រោយក្នុងរបាយការណ៍នេះជាពិសេសផលប៉ះពាល់ដែលអាចមានកើតឡើងពីការពន្យាពេលនៃការទម្លាក់ថវិកា។

## A: *ការរៀបចំថវិកា*

សកម្មភាពនិងដំណើរការរៀបចំផែនការពីថ្នាក់ក្រោមទៅលើត្រូវបានចែងក្នុងគោលការណ៍ណែនាំថ្នាក់ជាតិ ហើយការបណ្តុះបណ្តាលបានត្រូវផ្តល់ឱ្យដល់អ្នកដែលពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានថ្នាក់ស្រុក និងថ្នាក់ខេត្ត ដើម្បីរៀបចំផែនការ និងថវិកា។ ទោះជាយ៉ាងនេះក្តី យើងរកឃើញភស្តុតាងតិចតួចស្តួចស្តើងដែលថាការរៀបចំផែនការថវិកាពីថ្នាក់ក្រោមទៅលើជាការអនុវត្តទូទៅ ។ ជាលទ្ធផលប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ទាំងអស់ជានិច្ចកាលបានរង់ចាំការទម្លាក់ថវិកា និងការណែនាំពីមន្ទីរអប់រំខេត្តឬការិយាល័យអប់រំស្រុក ដើម្បីរៀបចំផែនការសកម្មភាព។

ការរំពឹងទុកអំពីការរៀបចំផែនការត្រូវបានបញ្ជាក់ក្នុងគោលការណ៍ណែនាំនានា អំពីមជ្ឈមណ្ឌលសិក្សាសហគមន៍។ មជ្ឈមណ្ឌលសិក្សាសហគមន៍ ការិយាល័យអប់រំស្រុក មន្ទីរអប់រំខេត្ត និងនាយកដ្ឋានអប់រំក្រៅប្រព័ន្ធត្រូវបានតម្រូវឱ្យរៀបចំសង្ខេបរួម និងប្រគល់ផែនការតាមលំដាប់ថ្នាក់ពីក្រោមឡើងលើ។

បើយោងតាមគោលការណ៍ណែនាំ ប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ចាំបាច់ត្រូវតែចូលរួមក្នុងដំណើរការរៀបចំផែនការដោយកំណត់នូវវគ្គបណ្តុះបណ្តាលណាដែលសហគមន៍ត្រូវការ រួចដាក់ស្នើផែនការសកម្មភាព និងថវិកាដល់ការិយាល័យអប់រំស្រុក។ ប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍សឹងតែគ្រប់គ្នាបានបញ្ជាក់ថា ពួកគេបានទទួលការបណ្តុះបណ្តាលលើការវាយតម្លៃតម្រូវការសកម្មភាព និងការរៀបចំផែនការថវិកា។ ដោយសារមជ្ឈមណ្ឌលសិក្សាសហគមន៍មានគោលបំណងផ្តល់ការបណ្តុះបណ្តាលឬព័ត៌មានដែលសហគមន៍ត្រូវការ ការណែនាំបានចែងថា ការរៀបចំផែនការគួរតែបញ្ចូលសហគមន៍ (ឧទាហរណ៍ គណៈកម្មាធិការមជ្ឈមណ្ឌលសិក្សាសហគមន៍ គ្រូជំនាញមុខរបរ និងអ្នកដែលអាចក្លាយជាសិស្ស)។ សំណូមពរទាំងនេះគួរត្រូវបានដាក់បញ្ចូលគ្នាដោយការិយាល័យអប់រំស្រុក និងការិយាល័យអប់រំខេត្ត ដើម្បីប្រគល់ជូននាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៅថ្នាក់ជាតិ។ ដ្យាក្រាមខាងក្រោម នេះបង្ហាញពីដំណើរការនេះ។

ការបង្ហាញពីគំរូនៃការរៀបចំផែនការថវិកា៖ គំរូពីក្រោមឡើងលើ




*តួនាទីរបស់ប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ (ម.ស.ស)*

ការចូលរួមរបស់ប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ក្នុងការរៀបចំផែនការថវិកាត្រូវបានរកឃើញថានៅមានកម្រិត។ ប្រធានម.ស.ស៤នាក់ក្នុងចំណោម២១នាក់ ដែលផ្តល់បទសម្ភាសន៍បាន បញ្ជាក់ថាពួកគេបានផ្ញើផែនថវិការបស់ពួកគេឱ្យការិយាល័យអប់រំស្រុកតាមការសំណូមពរ។ ប្រធានម.ស.សចំនួន១៧នាក់ទៀត ជានិច្ចជាកាលរៀបរាប់ថាពួកគេ មិនត្រូវបានប្រាប់ដោយការិយាល័យអប់រំស្រុកឱ្យប្រគល់ផែនការលើក្រដាសទេ។ ក្នុងខេត្តចំនួន៣ គ្មានប្រធានម.ស.សណាម្នាក់ប្រាប់ថាបានប្រគល់ផែនការថវិកាឡើយ។ ក្នុងខេត្ត២ អ្នកគ្រប់គ្រងម.ស.សបានប្រាប់ថាពួកគេបានប្រគល់ ផែនការសកម្មភាព ប៉ុន្តែមិនមានថវិកា ហើយក្នុងខេត្តមួយទៀត ទាំងផែនការសកម្មភាព និងថវិកាមិនត្រូវបានប្រគល់ជូនថ្នាក់លើទេ។

ជារួម ៧៦% នៃប្រធានម.ស.សមិនបានប្រគល់ទាំងផែនការថវិកាឬសកម្មភាព បើទោះជាប្រធានម.ស.សមួយចំនួននិយាយថា បានផ្តល់ព័ត៌មានទៅអោយការិយាល័យអប់រំស្រុកឬមន្ទីរអប់រំ

ខេត្តអំពីមជ្ឈមណ្ឌលសិក្សាសហគមន៍(ម.ស.ស)របស់ពួកគេក៏ដោយ (ឧទាហរណ៍ ចំនួនថ្នាក់ពួកគេចង់ផ្តល់ចំនួនគ្រូជំនាញមុខរបរ) នៅពេលសួរផ្ទាល់ ឬតាមរយៈទូរស័ព្ទ។

| | ម.ស.ស ដែលបានប្រគល់ផែនការសកម្មភាព | ម.ស.ស ដែលបានប្រគល់ផែនការថវិកា | ម.ស.ស ដែលមិនបានប្រគល់ផែនការសកម្មភាព/ថវិកា |
|---|---|---|---|
| ខេត្តលេខ១ | 25% | 0% | 75% |
| ខេត្តលេខ២ | 0% | 25% | 75% |
| ខេត្តលេខ៣ | 0% | 40% | 60% |
| ខេត្តលេខ៤ | 33% | 0% | 67% |
| ខេត្តលេខ៥ | 0% | 0% | 100% |

*តារាង៤៖ ផែនការថវិកា និងសកម្មភាពដែលបានប្រគល់ជូនមន្ទីរអប់រំខេត្ត*

គួរឱ្យកត់សម្គាល់ដែរថា មជ្ឈមណ្ឌលសិក្សាសហគមន៍(ម.ស.ស) ក្នុងខេត្តលេខ១ដែលប្រធានម.ស.សភាគច្រើនមិនបានប្រគល់ផែនការសម្រាប់ឆ្នាំ២០១៤បានបញ្ជាក់ថាពួកគេបានធ្លាប់ត្រូវបានសួរដោយការិយាល័យអប់រំស្រុកឱ្យប្រគល់ផែនការថវិកាសម្រាប់ឆ្នាំ២០១៥ ដែលអាចឆ្លុះបញ្ចាំងពីការកែលម្អការអនុវត្ត។

ប្រធានម.ស.សភាគច្រើនមិនបានពន្យល់ពីមូលហេតុដែលពួកគេមិនត្រូវបានសួររកឯកសារទាំងនោះទេ ប៉ុន្តែមិនបានរៀបចំផែនការថវិកាកាលពីឆ្នាំ២០១៤ ដោយសារទំហំនៃការងារស្មុគស្មាញ ឧទាហរណ៍ ក្នុងនាមជានាយកសាលា ត្រូវចេះចាត់អាទិភាព។ បន្ថែមពីនេះទៅទៀត ប្រធានម.ស.ស ២នាក់បានបង្ហើបថាការិយាល័យអប់រំស្រុកឬមន្ទីរអប់រំខេត្តបានធ្វើការដោយផ្ទាល់ជាមួយគ្រូជំនាញក្នុងការរៀបចំផែនការថវិកា។

> ម.ស.ស១.២ *"ខ្ញុំមិនដែលធ្វើផែនការទេ ហើយក្រសួងក៏មិនដែលប្រាប់ខ្ញុំអំពីថវិកា ដែរ ខ្ញុំគ្រាន់តែអោយមន្ទីរអប់រំខេត្តធ្វើផែនការ (សម្រាប់ម.ស.សរបស់ខ្ញុំ)..."*

ប្រធានម.ស.សម្នាក់បានបង្ហើបថាពួកគេយល់ថាការងារស្នូលមួយរបស់ពួកគេក្នុងការប្រតិបត្តិការមជ្ឈមណ្ឌលសិក្សាសហគមន៍ គឺការរើសគ្រូជំនាញនិងមិនបានគិតគូរអំពីការរៀបចំផែនការថវិកាថាជាចំណែកធំនៃការងាររបស់ពួកគេទេ។ វាគួរត្រូវបានបញ្ជាក់ថាប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍(មស.ស.) ជា

ច្រើនធ្លាប់ជានាយកសាលា ឬ នាយករងនៃសាលាបឋមសិក្សាឬអនុវិទ្យាល័យដែលមជ្ឈមណ្ឌលសិក្សាសហគមន៍ស្ថិតនៅ។ ពួកគេត្រូវបានរាយការណ៍ថាមិនធ្លាប់ទទួលបានអត្ថប្រយោជន៍ផ្នែកថវិកាណាឡើយសម្រាប់ការងារបន្ថែមលើមជ្ឈមណ្ឌលសិក្សាសហគមន៍។

នៅពេលសួរអំពីការមានជំនឿចិត្តក្នុងការរៀបចំផែនការមជ្ឈមណ្ឌលសិក្សាសហគមន៍(ម.ស.ស) ៩០%នៃប្រធានម.ស.ស និយាយថា ពួកគេមានជំនឿចិត្តក្នុងការធ្វើវាបានល្អ ប្រសិនបើការិយាល័យស្រុក ឬមន្ទីរអប់រំ ខេត្តតម្រូវឱ្យពួកគេធ្វើ។ ៩០%និយាយថា បានធ្លាប់ចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាផ្សេងៗ អំពីការគ្រប់គ្រង និងការធ្វើផែនការក្រោមការរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា។

*រូបភាព៣៖ ជំនឿចិត្តរបស់ប្រធានម.ស.សក្នុងការរៀបចំផែនការថវិកា*




*រូបភាព៤៖ វគ្គបណ្តុះបណ្តាលដែលប្រធានមជ្ឈមណ្ឌលសហគមន៍បានទទួលការបំប៉នលើការរៀបចំ ផែនការថវិកា និងសកម្មភាព*



## តួនាទីរបស់ការិយាល័យអប់រំស្រុក

ជាការគួរអោយចាប់អារម្មណ៍ ខណៈពេលដែលប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ ភាគច្រើន-និយាយថាពួកគេមិនដែលធ្វើផែនការណាមួយទេ មន្ត្រីការិយាល័យអប់រំស្រុក ៦នាក់ក្នុងចំណោម ១១នាក់ បានរៀបរាប់ថាពួកគេធ្លាប់បានទទួលផែនការពីប្រធានមជ្ឈមណ្ឌល និងធ្លាប់បានពិនិត្យឡើងវិញ និងធ្វើសង្ខេបរួមផែនការទាំងនោះមុនពេលប្រគល់ឱ្យមន្ទីរអប់រំខេត្ត។ វាអាចទៅរួចដែលការអធិប្បាយទាំងអស់នេះសំដៅលើការពិភាក្សាតាមទូរស័ព្ទជាជាងការរៀបចំផែនការជាផ្លូវការ និងលាយលក្ខ័អក្សរដោយផ្ទាល់។ ទោះជាយ៉ាងនេះក្តី ការណ៍នេះមានន័យថា មន្ត្រីការិយាល័យអប់រំស្រុកមួយចំនួនធំបានរៀបរាប់ថា បានបង្កើតផែនការថវិកាដោយខ្លួនគេផ្ទាល់ជាជាងអនុវត្តតាមដំណើរការរៀបចំពីក្រោមឡើងទៅលើ ដែលចាប់ផ្តើមពីប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍(ម.ស.ស)។

ដូច្នេះតួនាទីរបស់មន្ត្រីការិយាល័យអប់រំស្រុកក្នុងដំណើរការនេះ គឺបង្កើតនូវផែនការរួមគ្នាមួយសម្រាប់ស្រុកនានារបស់ពួកគេ។ តាមរយៈបទសម្ភាសន៍ មន្ត្រី៨នាក់ក្នុងចំណោម១១នាក់ ដែលមកពីការិយាល័យអប់រំស្រុកនិយាយថាពួកគេបានរៀបចំផែនការថវិកាហើយបានផ្ញើអោយមន្ទីរអប់រំខេត្តរបស់ពួកគេ។

| ផែនការថវិការបស់ ម.ស.ស ដែលបានប្រគល់ | ការិ.អប់រំស្រុក ទី១ | | ការិ.អប់រំស្រុក ទី២ | | ការិ.អប់រំស្រុក ទី៣ | |
|---|---|---|---|---|---|---|
| | បាទ/ចាស | ទេ | បាទ/ចាស | ទេ | បាទ/ចាស | ទេ |
| ខេត្តលេខ១ | | ✓ | ✓ | | | |
| ខេត្តលេខ២ | ✓ | | ✓ | | | ✓ |
| ខេត្តលេខ៣ | ✓ | | ✓ | | | |
| ខេត្តលេខ៤ | | ✓ | ✓ | | | |
| ខេត្តលេខ៥ | ✓ | | ✓ | | | |

*តារាង៣៖ ផែនការថវិកាដែលបានរៀបចំដោយការិយាល័យអប់រំស្រុក*

មន្ត្រី៣នាក់មកការិយាល័យអប់រំស្រុកឆ្លាយបាននិយាយថាផែនការថវិកាសម្រាប់ស្រុករបស់ពួកគេត្រូវបានរៀបចំដោយមន្ត្រីនៅមន្ទីរអប់រំខេត្តរបស់ពួកគេរៀងៗខ្លួន ហើយពួកគេមិនត្រូវបានស្នើឱ្យរៀបចំនោះទេ។ ពួកគេដឹងថាមន្ត្រីនៅមន្ទីរអប់រំខេត្តបានទំនាក់ទំនងជាមួយប្រធានម.ស.ស ឬគ្រូជំនាញផ្ទាល់ដើម្បីបានព័ត៌មាន។ មន្ត្រីនៅការិយាល័យអប់រំស្រុកម្នាក់ បានរៀបរាប់ពីការលំបាកក្នុងការរៀបចំ

ថវិកាដោយ សារតែកង្វះព័ត៌មានលើធនធានថវិកាជាមធ្យមដែលមានជាហេតុធ្វើឱ្យការរៀបផែនការថវិកាពិបាក។ មន្ត្រីនៅការិយាល័យអប់រំស្រុកម្នាក់ទៀតបានប្រាប់ថាមិនមានការស្នើសុំផែនការថវិកាពីខាងមន្ទីរអប់រំខេត្តមិនមានការផ្តល់ការបណ្តុះបណ្តាលលើការរៀបចំផែនការ និងមិនមានទម្រង់ផែនការចែករំលែកឡើយ បើទោះបីជាវាផ្ទុយទៅនឹងខ្លឹមសារផ្សេងៗនៅក្នុងគោលការណ៍ណែនាំស្តីអំពីការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍(ម.ស.ស)ក៏ដោយ។

មន្ត្រីការិយាល័យអប់រំស្រុកខ្លះបានប្រាប់ថា បានចូលរួមក្នុងការប្រជុំលើការរៀបចំផែនការដែលរៀបចំដោយមន្ទីរអប់រំខេត្តដើម្បីពិភាក្សាពីផែនការថ្នាក់ខេត្ត។

> ការិយាល័យអប់រំស្រុក៣.១៖ *"ខ្ញុំមានផែនការជាច្រើនដែលបានមកពីមជ្ឈមណ្ឌលសិក្សាសហគមន៍ ខ្ញុំបានពិនិត្យឡើងវិញនិងបានប្រគល់ជូនទៅមន្ទីរអប់រំខេត្ត។"*
>
> ការិយាល័យអប់រំស្រុក១.១៖ *"ខ្ញុំមិនដែលចាំបាច់ត្រូវប្រគល់ផែនការទេ។ មន្ត្រីនៅមន្ទីរ អប់រំខេត្ត សួរទៅកាន់ប្រធានម.ស.សដោយផ្ទាល់អំពីតម្រូវការរបស់ពួកគេហើយពួកគេរៀបចំផែនការជំនួសប្រធានម.ស.សតែម្តង។ ខ្ញុំមិនទាំងដឹងថាពេលណា ពួកគេត្រូវការផែនការផង។"*

ស្រដៀងគ្នាទៅហ្នឹងប្រធានម.ស.ស មន្ត្រីនៅការិយាល័យអប់រំស្រុកដែលមិនបានរៀបរាប់ពីតួនាទីក្នុងការរៀបចំផែនការសម្រាប់ឆ្នាំ២០១៤បាននិយាយថា ប្រសិនបើមន្ទីរអប់រំខេត្តតម្រូវឱ្យពួកគេប្រគល់ជូនផែនការថវិកាប្រចាំឆ្នាំ ម្ល៉េះសមពួកគេមានទំនុកចិត្តក្នុងការធ្វើដូច្នោះ ពីព្រោះពួកគេធ្លាប់បានទទួលការបណ្តុះបណ្តាលដែលពាក់ព័ន្ធ ជាពិសេសលើការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍។

## *តួនាទីរបស់មន្ទីរអប់រំខេត្ត*

បទសម្ភាសន៍ជាមួយមន្ត្រីតំណាងមកពីមន្ទីរអប់រំខេត្តដែលត្រូវបានសិក្សាបានទទួលស្គាល់ថាមន្ត្រីមកពីមន្ទីរអប់រំខេត្តហាក់មានទំនួលខុសត្រូវក្នុងការសម្របសម្រួលនិងធ្វើអោយល្អនូវថវិកានិងសកម្មភាពដែលបានរៀបចំរួចពីស្រុកទាំងអស់នៅក្នុងខេត្តរបស់ពួកគេ។ គណនេយ្យករ នៅមន្ទីរអប់រំខេត្តបានទំនួលខុសត្រូវក្នុងការធ្វើអោយល្អនូវថវិកាដោយប្រើទម្រង់គំរូមួយ ដែលបង្កើតដោយនាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួង អប់រំ យុវជន និងកីឡា នៅឯថ្នាក់កណ្តាល។

មន្ត្រីមកពីមន្ទីរអប់រំខេត្ត៣នាក់បាននិយាយថា មន្ត្រីការិយាល័យអប់រំស្រុកខ្លះមិនបានផ្ញើផែនការនិងសកម្មភាពដែលបានរៀបរួច។ ខេត្ត៤ក្នុងចំណោម៥បានបញ្ជាក់ថា ពួកគេបានធ្វើសឹងតែគ្រប់ការងារពាក់ព័ន្ធនឹងការរៀបចំផែនការពីព្រោះតែមិនមានព័ត៌មានលម្អិតពីការិយាល័យអប់រំស្រុក និងមជ្ឈមណ្ឌល។ មុនពេលរៀបចំផែនការថវិកាលម្អិត មន្ត្រីមកពីមន្ទីរអប់រំខេត្តខ្លះបានរៀបចំការប្រជុំស្តីពីការធ្វើផែនការជាមួយនឹងការិយាល័យអប់រំស្រុកនិងម.ស.ស ដើម្បីកំណត់ពីអាទិភាពនិងតម្រូវការរបស់ពួកគេ។

ក្នុងករណីខ្លះ មន្ត្រីមកពីមន្ទីរអប់រំខេត្ត បានបញ្ជាក់ថាពួកគេបានហៅគ្រូជំនាញដោយផ្ទាល់ដើម្បីសួរអំពីមុខជំនាញនិងសម្ភារៈដែលពួកគេអាចនឹងត្រូវការនៅពេលខាងមុខ។

> មន្ទីរអប់រំខេត្ត១៖ *"ខ្ញុំបានទទួលផែនការថវិកាពីការិយាល័យអប់រំស្រុក។ ខ្ញុំគ្រាន់តែបានទទួលសំណូមពរលើសម្ភារៈដែលស្នើដោយគ្រូជំនាញតែប៉ុណ្ណោះ។"*
>
> មន្ទីរអប់រំខេត្ត៥៖ *"ខ្ញុំមិនដែលបានទទួលផែនការថវិកាពីម.ស.សឬការិយាល័យ អប់រំស្រុក ទេពីព្រោះផែនការថវិកានេះជានិច្ចកាលត្រូវបានរៀបចំដោយថ្នាក់លើ។ ប្រសិនបើយើងស្នើឱ្យថ្នាក់ក្រោមរៀបចំ យើងនឹងមិនអាចឆ្លើយតបនឹងតម្រូវការឡើយ។"*

បើទោះជាផែនការថវិកាត្រូវបានរៀបចំឡើងដោយថ្នាក់មជ្ឈមណ្ឌលថ្នាក់ស្រុក ឬខេត្ត យ៉ាងណាក៏ដោយក៏នៅថ្នាក់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ផែនការទាំងនោះនឹងត្រូវបានត្រួតពិនិត្យឡើងវិញ និងដាក់បញ្ចូលគ្នាទៅក្នុងផែនការតែមួយដើម្បីឆ្លងការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា ហើយប្រគល់ឱ្យក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ ដូចជាចំណែកនៃថវិការបស់ក្រសួងអប់រំ។

## *បញ្ហាក្នុងការរៀបចំផែនការថវិកា*

ដំណើរការរៀបចំផែនការថវិកាពីថ្នាក់ក្រោមឡើងលើ ដែលត្រូវបានចែងក្នុងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងម.ស.ស ហាក់មិនដំណើរការបានក្នុងខេត្តដែលយើងសិក្សា។ កត្តាជំរុញការណ៍នេះអាស្រ័យទៅតាមគំនិតរបស់អ្នកឆ្លើយសំនួរ គឺអាចជាកង្វះការឆ្លើយតបទៅកាន់ការស្នើសុំព័ត៌មានពីម.ស.ស នៅថ្នាក់មូលដ្ឋានឬពីថ្នាក់ស្រុក ឬក៏ការពេញចិត្តពីមន្ទីរអប់រំខេត្តក្នុងការទទួលបំពេញតួនាទីជាអ្នកធ្វើផែនការ ។

បទសម្ភាសន៍ជាមួយមន្ទីរអប់រំខេត្តបានបង្ហាញថា តាមកម្រិតនៃការឆ្លើយតបរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍និងការិយាល័យអប់រំស្រុក ការរៀបចំផែនការបែបថ្នាក់កណ្តាល គឺជាគំរូមួយដែលមានប្រសិទ្ធភាពបំផុត ហើយធ្វើឱ្យមានចន្លោះប្រហោងផ្នែកការផ្តល់ព័ត៌មាននៅឯថ្នាក់មូលដ្ឋាន។ បន្ថែមពីនេះទៀត ផែនការដែលរៀបចំពីថ្នាក់ក្រោមហាក់ មិនជាក់ស្តែង ឬហាក់មិនអាចរ៉ាប់រងបាន បើយោងតាមថវិកាដែលមាន។ នេះជារឿងគួរឱ្យ កត់សម្គាល់មួយដោយសារតែមានរូបមន្តថ្នាក់ជាតិមួយដែលគូសបញ្ជាក់ពីកម្រិតនៃធនធានសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍នីមួយៗ។ វាអាចបកស្រាយបាន២ថាមួយផែនការដែលបានបង្កើតនៅថ្នាក់មូលដ្ឋានមិនបានគិតពិចារណាពីរូបមន្តនេះទេ ឬមួយទៀតថាមន្ត្រីមន្ទីរអប់រំខេត្តមិនបានជឿថា រូបមន្តនេះអាចប្រើបាននៅពេលដែលពួកគេបានទទួលការបែងចែកថវិកាដ៏ពិតប្រាកដមែន។

ការបណ្តុះបណ្តាលបានផ្តល់ដល់អ្នកគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍(ម.ស.ស) និងមន្ត្រីការិយាល័យអប់រំស្រុកដែលបានបញ្ចូលការរៀបចំផែនការថវិកានិងសកម្មភាពសម្រាប់ម.ស.ស ប៉ុន្តែជំនាញ ទាំងនេះមិនត្រូវបានប្រើប្រាស់សម្រាប់ម.ស.សភាគច្រើន។ ទម្លាប់ល្អមួយត្រូវបានរកឃើញក្នុងខេត្តមួយនៅពេលដែលការប្រជុំលើការរៀបចំផែនការមួយត្រូវបានធ្វើដើម្បីបញ្ចៀសភាពលំបាកក្នុងការទទួលបានព័ត៌មានពីតំបន់មូលដ្ឋាន។

## B: *ការវិភាជថវិកា*

បើទោះបីជាទ្រឹស្តីមានរូបមន្តថ្នាក់ជាតិមួយសម្រាប់វចិការបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ក៏ដោយ ក៏ការបែងចែកថវិកាពិតប្រាកដមានភាពខុសគ្នាពីរូបមន្តនេះនៅឆ្នាំ២០១៤។ បន្ថែមពីនេះទៅទៀតពួកយើង រកឃើញពីកង្វះនៃការយល់ដឹងថាថវិកាដែលនឹងត្រូវវិភាជជាចុងក្រោយទៅម.ស.ស នៅថ្នាក់ស្រុក និងសហគមន៍។ នេះរារាំងដល់បំណងចង់អោយមានគណនេយ្យភាពនិងតម្លាភាពរបស់សហគមន៍។ វាក៏បង្ហាញថាម.ស.ស ជានិច្ចកាល មិនគ្រប់គ្រងថវិកាដោយខ្លួនឯងឡើយ។

### *ការវិភាជថវិការបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធទៅតាមបណ្តាខេត្ត*

មន្ទីរអប់រំខេត្តប្រគល់ផែនការសកម្មភាពនិងថវិកាដែលបានបញ្ចូលគ្នារួចទៅអោយនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ។ ពេលដែលផែនការនេះត្រូវបានប្រគល់ហើយថវិកាដែលស្នើសុំត្រូវបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ បន្ទាប់មកក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានអប់រំក្រៅប្រព័ន្ធមានតួនាទីបែងចែកថវិកាដែលមានទៅអោយខេត្តផ្សេងៗទៅតាម ចំនួននៃមជ្ឈមណ្ឌលសិក្សាសហគមន៍និងទៅតាមផែនការសកម្មភាពទាំងនោះ។

នៅខែធ្នូ ឆ្នាំ២០១៣ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធបានចេញឯកសារមួយច្បាប់ហៅថា ការអនុវត្តនិងវិភាជថវិកាកម្មវិធីឆ្នាំ២០១៤ សម្រាប់កម្មវិធីអប់រំក្រៅប្រព័ន្ធ។ ឯកសារនេះបញ្ចូលសំណៅយោងប្រកាសអន្តរក្រសួងលេខ ៥០៨ ដែលផ្តល់ការណែនាំថាមជ្ឈមណ្ឌលសិក្សាសហគមន៍នីមួយៗគួរទទួលបានថវិកា ១០លានរៀលជារៀងរាល់ឆ្នាំ។ តារាងមួយក្នុងឯកសារនោះបានបង្ហាញពីថវិកាសម្រាប់ការចំណាយលើកម្មវិធីក្នុងឆ្នាំ២០១៤ ដោយកម្មវិធីអប់រំក្រៅប្រព័ន្ធរង (ទំព័រ ១៦)។ អត្ថបទក្នុងតារាងនោះបានបង្ហាញពីការបែងចែកថវិកាជាប៉ាន់ប្រមាណ ៩.១លានរៀល សម្រាប់មជ្ឈមណ្ឌលសិក្សានីមួយៗដែលខុសពីប្រកាសអន្តរក្រសួងលេខ ៥០៨។ ថវិកាសរុបដែលពាក់ព័ន្ធនឹងខ្ទង់ចំណាយនេះគឺ ២៧១៩លានរៀល ដែលប្រហាក់ប្រហែលនឹង ៨.៤លានរៀល សម្រាប់ម.ស.សមួយៗ (ឬ២០៩៨ដុល្លា)។ អត្ថបទនិងថវិកាសរុបរួមក្នុងតារាងមិនសមមូលគ្នាទេ ហើយវាមិនសមមូលតាមប្រកាសអន្តរក្រសួងទៀតផង ដែលអាចផ្តល់ឱ្យយើងនូវការយល់មួយចំនួនទៅក្នុងភាពស្មុគ្រស្មាញនៃការវិភាជថវិកានិងដំណើរការ។

នេះទំនងជាលទ្ធផលនៃការចរចារគ្នាទាំងនៅក្នុងនិងរវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅពេលបែងចែកថវិកាចុងក្រោយសម្រាប់ឆ្នាំនោះ។ វាជាការសន្និដ្ឋាន

របស់យើងដែលថាថវិកាសរុបរួមត្រូវបានបន្ថយពីចំនួនដែលបានសំណូមពរពីដើម ហើយការវិភាជសារឡើងវិញពិតជាចាំបាច់ក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ ប៉ុន្តែរូបមន្តដែលបានកត់ត្រាក្នុងអត្ថបទមិនត្រូវបានធ្វើបច្ចុប្បន្នភាពទេ។

នេះគឺជាកំហុសឆ្គងដែលអាចយល់បាន ប៉ុន្តែអាចបង្កការយល់ច្រលំមួយចំនួននៅថ្នាក់មូលដ្ឋាន។ ឯកសារដែលនិយាយពីការបែងចែកថវិកាកម្មវិធីបានបង្ហាញពីថវិកាអប់រំក្រៅប្រព័ន្ធសម្រាប់ខេត្តតាមជំពូក និងបញ្ជីបន្ទាប់ (ឧទាហរណ៍ ប្រភេទនៃការចំណាយ) ជាជាងផ្អែកតាមកម្មវិធី។ វាហាក់ដូចជាមានហេតុផលដែលមន្ទីរអប់រំខេត្តអាចយល់ថាវាមានភាពប្រែប្រួលក្នុងរចនាសម្ព័ន្ធ ឬក៏អាចមិនច្បាស់ថាអ្វីគួរតែត្រូវបានចំណាយលើម.ស.ស ដោយមិនចាំបាច់ត្រូវការគណនាបន្ថែមទៀតដោយខ្លួនឯង។

មន្ទីរអប់រំខេត្ត៤ក្នុងចំណោម៥ ដែលត្រូវបានសម្ភាសន៍បានបញ្ជាក់ថាថវិការបស់ពួកគេ ក្រោយពេលព្រមព្រៀងគឺតិចជាងចំនួនដែលពួកគេបានសំណូមពរ។ នៅពេលដែលសួរថាអ្នកណាបានចូលរួមក្នុងការផ្លាស់ប្តូរថវិកា ក្នុងករណីជាច្រើនពួកគេឆ្លើយថាគឺអគ្គនាយកដ្ឋានអប់រំក្រៅប្រព័ន្ធដែលមានសមត្ថកិច្ចក្នុងការសម្រេចចំនួនថវិកាដែលខេត្តមួយៗគួរទទួលបានដោយយោងតាមថវិកាថ្នាក់ជាតិដែលត្រូវបានព្រមព្រៀងឱ្យ។ ពីព្រោះការណែនាំលើថវិកាដែលមាន មិនបញ្ជាក់ពីការបែងចែកទៅអោយខេត្តតាមកម្មវិធី ប៉ុន្តែតាមប្រភេទនៃការចំណាយទៅវិញ វាមិនអាចទៅរួចក្នុងការពិនិត្យមើលថាតើខេត្តផ្សេងៗគ្នាទទួលបានចំនួនថវិកាខុសគ្នាទៅតាមកម្មវិធីមជ្ឈមណ្ឌលសិក្សាសហគមន៍របស់វា។

ខេត្តចំនួន៤ដែលបានពណ៌នាថាការបែងចែកថវិកាចុងក្រោយ គឺមានចំនួនយ៉ាងហោចណាស់ ៥០% តិចជាងចំនួនដែលបានដាក់ស្នើ ឬរំពឹងទុក។ មន្ទីរអប់រំខេត្តមួយដែលបានប្រាប់ថា ពួកគេទទួលបានថវិកាមានចំនួនស្មើចំនួនដែលបានស្នើសុំនិយាយថា ពួកគេគោរពតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានស្នើថាថវិកាថ្មីមិនត្រូវច្រើនជាងថវិកា ឆ្នាំមុន៥%ឡើយ។ នេះប្រហែលជាអាចបញ្ជាក់បានថាខេត្តផ្សេងៗមិនគោរពតាមការណែនាំនេះ ប៉ុន្តែវាពិបាកក្នុងការចង្អុលបង្ហាញឱ្យច្បាស់ណាស់ ពីព្រោះភស្តុតាងនៃការស្នើថវិកាមិនត្រូវបានចែករំលែកជាមួយអ្នកស្រាវជ្រាវឡើយ។

## *ការបែងចែកថវិការបស់មន្ទីរអប់រំខេត្តដល់ការិយាល័យអប់រំស្រុកនិងមជ្ឈមណ្ឌលសិក្សាសហគមន៍*

ខេត្តចំនួន២ក្នុងចំណោមខេត្ត៥ដែលពណ៌នាថាពួកគេបានបែងចែកថវិកាម.ស.ស ពួកគេទៅឱ្យម.ស.សនីមួយៗតាមរូបមន្តរបស់ថ្នាក់ជាតិ។ ខេត្តចំនួន៣ផ្សេងទៀតបានប្រាប់ថាបានធ្វើការលៃតម្រូវទៅតាមការយល់ឃើញរបស់ពួកគេទៅលើតម្រូវការ និងគ្រូជំនាញដែលមាននៅតាមមូលដ្ឋាន ដូច្នេះមជ្ឈមណ្ឌលសិក្សាសហគមន៍ផ្សេងគ្នាទទួលបានចំនួនថវិកាខុសៗគ្នាដែរ។ ដូចដែលយើងនឹងគូសបញ្ជាក់ខាងក្រោម ការផ្តល់អោយនូវសម្ភារៈ និងឧបករណ៍ដែលបានទិញយ៉ាងច្រើនទៅឱ្យម.ស.ស

(ជាជាងថវិកាជាសាច់ប្រាក់) ជារឿងសាមញ្ញ ដូច្នេះហើយខេត្តខ្លះមិនអាចដឹងថាថវិកាប៉ុន្មាន ត្រូវបានចំណាយលើម.ស.ស នីមួយៗ។

មន្ត្រីមន្ទីរអប់រំខេត្តជាច្រើនបានរៀបរាប់ថាពួកគេចាំបាច់ត្រូវបន្ថយឬកាត់វគ្គសិក្សាអោយខ្លីដើម្បីឱ្យស្របនឹងថវិកាថ្មី ហើយធ្វើការសម្រេចចិត្តលើស្រុកមួយណានឹងទទួល ឬសកម្មភាពណាខ្លះដែលត្រូវបានអនុញ្ញាតអោយធ្វើនៅតាមម.ស.សនីមួយៗ។ បើប្រើដំណើរការរៀបចំផែនការតាមរបៀបពីក្រោមឡើងទៅលើចាប់មន្ទីរអប់រំខេត្ត ដំណើរការពីលើមកក្រោមទេដែលត្រូវបានប្រើក្នុងការធ្វើផែនការថ្មីដោយពឹងលើថវិកាដែលមានស្រាប់។

មន្ទីរអប់រំខេត្ត និងការិយាល័យស្រុកក្នុងខេត្តចំនួន៣ដែលផ្តល់បទសម្ភាសន៍បានបញ្ជាក់ពីការសម្រេចចិត្តក្នុងការកាត់បន្ថយចំនួនវគ្គ ឬសកម្មភាពដូចជាការប្រជុំផ្សេងៗ ពង្រួញរយៈពេលនៃវគ្គបណ្តុះបណ្តាល ឬប្តូរចំនួនសិស្សដើម្បីសម្របតាមថវិកាដែលបានបែងចែកឱ្យ។ ការិយាល័យអប់រំស្រុកមួយបានប្រាប់ថាតម្រូវការបានផ្លាស់ប្តូរក្នុងសហគមន៍ដូច្នេះពួកគេបានកែផែនការសកម្មភាពនៅពេលនេះដើម្បីអោយស្របតាមថវិកាដែលមាន។

បើយោងតាមមន្ទីរអប់រំខេត្តមួយ ក្រោយពេលការអនុម័តថវិកា នាយកដ្ឋានអប់រំក្រៅប្រព័ន្ធបានផ្ញើសៀវភៅផែនការថវិកាដែលបានអនុម័តទៅឱ្យមន្ទីរអប់រំខេត្តនានា។ បន្ទាប់មកមន្ទីរអប់រំខេត្តចែកចាយសៀវភៅទៅកាន់ការិយាល័យអប់រំស្រុក និងម.ស.សក្នុងកិច្ចប្រជុំរាយការណ៍ប្រចាំឆ្នាំរបស់ខេត្ត។ ប៉ុន្តែគ្មានការិយាល័យអប់រំស្រុក និងម.ស.ស ណាមួយ ប្រាប់ថាបានទទួលព័ត៌មាននេះទេ។

៧០%នៃការិយាល័យអប់រំស្រុកបានដឹងថាថវិកាបានអនុម័តសម្រាប់ស្រុករបស់ពួកគេ ហើយអាចបង្ហាញពីតួលេខបាន។ ចំណែកឯ៣០%ទៀតនិយាយថាពួកគេមិនបានដឹង ឬដឹងមិនច្បាស់អំពីថវិកាទាំងមូលនោះទេ។




*រូបភាពទី៥៖ ការផ្សព្វផ្សាយពីថវិកាសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍ដែលបានអនុម័តក្នុងចំណោមការិយាល័យអប់រំ*

ផ្ទុយទៅវិញ ៧១%នៃប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍(ម.ស.ស)បានរៀបរាប់ថាពួកគេមិនដឹងពីចំនួនថវិកាដែលបានអនុម័តសម្រាប់មជ្ឈមណ្ឌលរបស់ពួកគេតាមឆ្នាំនោះឡើយ។ ក្នុងខេត្តចំនួន២គ្មានប្រធានម.ស.សណាម្នាក់ដែលដឹងអំពីថវិកាដែលបានបែងចែក។ វាងាយស្រួលជាងក្នុងការយល់បើផ្អែកលើយោបល់ខាង ដើមអំពីធម្មជាតិនៃការងារពាក់កណ្តាលម៉ោងរបស់អ្នកគ្រប់គ្រងមជ្ឈមណ្ឌលឬការយល់ផ្សេងគ្នាទៅលើតួនាទីរបស់ពួកគេ។ ប្រធានម.ស.សជាច្រើនបានរាយការណ៍ថាពួកគេមិនបានស្វែងរកព័ត៌មានថវិកា ទេពីព្រោះទីបំផុតពួកគេមិនបានត្រួតត្រាការចំណាយផង។




*រូបភាព៦៖ ការដឹងពីថវិកាឆ្នាំ២០១៤ក្នុងចំណោមប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍*

## *មូលហេតុនៃការបែងចែកថវិកាសារជាថ្មី*

អ្នកចូលរួមឆ្លើយមកពីមន្ទីរអប់រំខេត្តក៏ដូចជាការិយាល័យអប់រំស្រុកបានពណ៌នាថាពួកគេត្រូវតែផ្តល់អាទិភាពដល់កម្មវិធីអប់រំក្រៅប្រព័ន្ធពីព្រោះកម្មវិធី ឬមជ្ឈមណ្ឌលសិក្សាសហគមន៍មិនទាំងអស់ទេដែលនឹងទទួលបានថវិកាក្នុងពេលដូចគ្នា ឬចំនួនដូចគ្នា។ អាស្រ័យហេតុនេះ ការបែងចែកថវិកាសារជាថ្មីត្រូវបានអនុវត្តហើយចេញជាលទ្ធផលនៃការពន្យាពេលការតម្លាក់ថវិកាខ្លះៗ។ ឧទាហរណ៍ ម.ស.សខ្លះបានទទួលថវិកា ហើយខ្លះទៀតត្រូវរងចាំដល់មួយជុំទៀតនៃការផ្ទេរពីថ្នាក់កណ្តាល។ លក្ខណៈវិនិច្ឆ័យដែលត្រូវបានប្រើក្នុងការចាត់អាទិភាពលើម.ស.ស ឬវគ្គបណ្តុះបណ្តាលមិនបានលេចចេញច្បាស់ពីបទសម្ភាសន៍នោះទេ។ ទោះជាយ៉ាងនេះក្តី អ្នកចូលរួមការសិក្សា២ ឬ៣នាក់បានរាយលក្ខណៈវិនិច្ឆ័យមួយចំនួនដូចជា ចម្ងាយនៃម.ស.ស ទំនាក់ទំនងទៅវិញទៅមកដ៏មានប្រសិទ្ធិភាពរវាងម.ស.សនិងការិយាល័យអប់រំស្រុក ឬមន្ទីរអប់រំខេត្ត និងភាពដែលអាចទុកចិត្តបានរបស់ម.ស.ស។ មន្ទីរអប់រំខេត្តតែមួយគត់ដែលបានរាយការណ៍ថាធ្លាប់បានប្រជុំមុនពេលសម្រេចចិត្តក្នុងការចាត់អាទិភាពថវិកាជាថ្មី។

## C: ការទម្លាក់ថវិកា

ការសិក្សានេះរកឃើញថារបៀបនៃការចំណាយថវិកាកំពុងត្រូវបានប្រើប្រាស់ខុសពីគោលការណ៍ណែនាំនៅថ្នាក់ជាតិ។ ខេត្តមួយត្រូវបានរកឃើញថាគោរពតាមគោលការណ៍ណែនាំជាទូលំទូលាយ។ ក្នុងករណីមួយចំនួនតូចម.ស.សផ្តល់ការចំណាយជាសាច់ប្រាក់។ ក្នុងករណីជាច្រើនទៀត ការិយាល័យអប់រំស្រុក ឬមន្ទីរអប់រំខេត្ត ជាអ្នកគ្រប់គ្រងថវិកានឹងផ្តល់ឯកសារ ឬឧបករណ៍ដោយផ្ទាល់ទៅកាន់ម.ស.សហើយបើកប្រាក់បៀវត្សឱ្យគ្រូជំនាញដោយផ្ទាល់។ បន្ថែមពីនេះទៅទៀត ការទម្លាក់ថវិកានិងការទូទាត់ប្រាក់បៀវត្សត្រូវបានរាយការណ៍ថាមានដំណើរការយឺតយ៉ាវយ៉ាងខ្លាំងហើយជាទូទៅត្រលប់ទៅរកអតីតកាល ។

## ដំណើរការ និងឋានានុក្រមនៃការទម្លាក់ថវិកា

បើយោងតាមគោលការណែនាំអំពីមជ្ឈមណ្ឌលសិក្សាសហគមន៍(ម.ស.ស) ថវិកាគួរត្រូវបានចំណាយដោយធ្វើទៅតាមឋានានុក្រមរដ្ឋបាលដូចបង្ហាញក្នុងដ្យាក្រាមខាងក្រោម។ ការិយាល័យអប់រំស្រុកនិងមន្ទីរអប់រំខេត្តគួរបញ្ជូនថវិកាជាសាច់ក្រាក់ទៅឱ្យមជ្ឈមណ្ឌលសម្រាប់ឱ្យ ពួកគេបើកប្រាក់បៀវត្សឱ្យគ្រូជំនាញមុខរបរដើម្បីទិញសម្ភារៈ និងបង់ថ្លៃការចំណាយទូទៅ ។



ក្នុងការអនុវត្ត យើងបានកំណត់គំរូនៃការទម្លាក់ថវិកាចំនួន៣ដែលត្រូវបានប្រើ ។ គំរូទាំងនេះត្រូវបានបង្ហាញយ៉ាងលម្អិតនៅទំព័របន្ទាប់។ ពួកវាមានចំណុចដូចគ្នាប៉ុន្តែចំណុចខុសគ្នាត្រង់វាប្រើវិធីសាស្ត្រមូលដ្ឋាន។

## *ការទម្លាក់ថវិកាគំរូទី១*




មានខេត្តមួយបានប្រើគំរូនេះ។ មានការផ្តល់ថវិកាចំនួន៩ដងត្រូវបានរៀបរាប់ថាបានផ្តល់ទៅការិយាល័យអប់រំស្រុករួចបន្តទៅកាន់ម.ស.ស ។ មន្ទីរអប់រំខេត្តនិងការិយាល័យអប់រំស្រុកក្នុងខេត្តនេះបាននិយាយថា ក្រោយពេលបានទទួលប្រាក់ពីរតនាគារខេត្ត មន្ទីរអប់រំហៅការិយាល័យអប់រំស្រុកដើម្បីទទួលបានប្រាក់ក្នុងការអនុវត្តសកម្មភាពរបស់ម.ស.ស។ក្រោយពេលទទួលប្រាក់ពីមន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុកបានទិញសម្ភារ:សម្រាប់ម.ស.សរបស់ពួកគេ ។ ដោយផ្អែកលើចម្លើយ របស់ការិយាល័យអប់រំ ស្រុក ពួកគេ(អប់រំស្រុក)និងគ្រូជំនាញទិញសម្ភារ:សម្រាប់ម.ស.សរបស់ពួកគេ។ប៉ុន្តែគ្មាន គ្រូជំនាញណាម្នាក់ដែលបានចូលរួមក្នុងក្រុមពិភាក្សាបានចូលរួមដំណើរជាមួយការិយាល័យអប់រំស្រុកក្នុងការរើសសម្ភារ:បណ្តុះបណ្តាលហើយមានការមិនពេញចិត្តxខ្លាំងលើសម្ភារ:ដែលបានផ្តល់អោយ។ប្រាក់បៀវត្សរបស់គ្រូជំនាញត្រូវបាន ប្រាប់ថាបាន ទទួលដោយផ្ទាល់ពីការិយាល័យអប់រំស្រុកជាជាងតាមរយ:ប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍(មសស)។

# ការទម្លាក់ថវិកាគំរូទី២




ខេត្តមួយបានពណ៌នាថាបានកំពុងប្រើម៉ូឌែលនេះ។ភាពខុសគ្នាពីម៉ូឌែលទីមួយគឺវាត្រូវបានប្រាប់ថាការិយាល័យអប់រំស្រុកនិងប្រធានម.ស.សបានទៅជាមួយគ្នាក្នុងការទទួលបានប្រាក់(សាច់ប្រាក់) ដោយផ្ទាល់ពីមន្ទីរអប់រំខេត្តតាមការស្នើរបស់មន្ទីរអប់រំខេត្ត។ភាពខុសគ្នាតែមួយពីគោលការណ៍ណែនាំគឺថាម.ស.សបានទទួលមូលនិធិរបស់ពួកគេដោយផ្ទាល់ពីមន្ទីរអប់រំខេត្តក្នុងពេលដូចជាជាមួយការិយាល័យអប់រំស្រុក។គ្រូជំនាញបានទទួលប្រាក់បៀវត្សរបស់ពួកគេពីប្រធានម.ស.ស។

# ការទម្លាក់ថវិកាគំរូទី៣




ខេត្តមួយបានពណ៌នាថាបានប្រើប្រាស់ម៉ូឌែលនេះ ពេលដែលការផ្ទេរសាច់ប្រាក់បានដល់មជ្ឈមណ្ឌល ដូច្នេះពួកគេអាចទូទាត់ប្រាក់បៀវត្សរបស់គ្រូជំនាញដោយផ្ទាល់។ ក្នុងខេត្តទាំងនេះ ម.ស.សខ្លះក៏ទទួលបានការទូទាត់ជាសាច់ប្រាក់សម្រាប់ការចំណាយទូទៅនិងសម្ភារៈខណៈពេលដែល ម.ស.សផ្សេងៗទទួលបានសម្ភារៈដែលបានទិញដោយការិយាល័យអប់រំស្រុក។

ខេត្តមួយមិនច្បាស់ថាប្រើគំរូនៃការបែងចែកថវិកាមួយណាទេ ពីព្រោះរហូតមកដល់ពេលនៃការប្រមូលទិន្នន័យចុងខែវិច្ឆិកាមិនមានការទម្លាក់ថវិកាដោយការិយាល័យអប់រំស្រុក និងមជ្ឈមណ្ឌលសិក្សាសហគមន៍ទេ។ ការិយាល័យអប់រំស្រុកដែលផ្តល់សម្ភាសន៍បានប្រាប់ថា ពួកគេបានទទួលព័ត៌មានអំពីថវិកាដែលត្រូវបានបែងចែកឱ្យម.ស.សរបស់ពួកគេ ប៉ុន្តែមិនបានទទួលលុយនៅឡើយ ដូច្នេះមិនអាចអត្ថាធិប្បាយពីការចំណាយទេ។

## *ការទម្លាក់ថវិកាជាក់ស្តែងធៀបនឹងថវិកាដែលអនុម័ត*

ការសិក្សានេះមានបំណងរកអោយឃើញភាពខុសគ្នារវាងថវិកាដែលម.ស.សបានទទួលជាក់ស្តែងបើធៀបនឹងថវិកាដែលបានអនុម័តពីថ្នាក់ជាតិឬមូលដ្ឋាន។ វាមិនអាចទៅរួចក្នុងការវិភាគរឿងនេះឱ្យច្បាស់លាស់ពីព្រោះវាមានគំរូនៃការទម្លាក់ថវិកាផ្សេងៗគ្នា ដែលរួមបញ្ចូលទាំងការទិញសម្ភារៈជាច្រើននៅកម្រិតការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត និងការរៀបចំទូទាត់លុយសម្រាប់ប្រាក់បៀវត្សគ្រូជំនាញ ពីព្រោះប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ភាគច្រើនមិនបានដឹងថាថវិកាណាដែលពួកគេត្រូវទទួលបាន ឬមិនទាន់ទទួលបានដើម្បីមកគ្រប់គ្រងដោយខ្លួនឯងនៅឡើយ។ បើទោះបីជាការសិក្សាត្រូវបានអនុញ្ញាតដោយមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក៏ដោយក៏មន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុកស្ទាក់ស្ទើរក្នុងការចែករំលែកភស្តុតាងជាឯកសារពីថវិកានៅកម្រិតម.ស.សនីមួយៗ បើទោះជាពួកគេបានពិភាក្សាពីថវិកាជាទូទៅក៏ដោយ។

មានភស្តុតាងខ្លះពីខេត្តមួយដែលការផ្ទេរជាសាច់ប្រាក់ក្លាយជាទម្លាប់ ដែលការចំណាយមានកម្រិតទាបជាងថវិកាដែលបានបញ្ជាក់ដែលជាលទ្ធផលនៃការសម្រេចចិត្តរបស់មន្ទីរអប់រំខេត្ត ឬការិយាល័យអប់រំស្រុកក្នុងការឱ្យអាទិភាពលើម.ស.ស និងសកម្មភាពផ្សេងៗ។ ហេតុដូច្នេះសកម្មភាពមួយចំនួនត្រូវបានលុបចោល។ អ្នកឆ្លើយតបម្នាក់បានលើកឡើងថាម.ស.សជាច្រើនមិនមានជាអាទិភាព សម្រាប់ការចំណាយថវិកា ដូច្នេះហើយថវិកាបានត្រូវបែងចែកសារជាថ្មីសម្រាប់ការអប់រំក្នុងប្រព័ន្ធវិញ ប៉ុន្តែការណ៍នេះ មិនអាចត្រូវបានផ្ទៀងផ្ទាត់ឡើយ។

មន្ទីរអប់រំខេត្តលេខ២៖ *"ពួកយើងបានចំណាយប្រាក់ទៅម.ស.សជាក់លាក់មួយចំនួនមុនដំបូងសិន នៅពេលថវិកាវិស័យអប់រំនៅគេនាគារមិនគ្រប់គ្រាន់។ ហើយមន្ទីរអប់រំខេត្តមានកម្មវិធីអាទិភាពផ្សេងទៀត [ដើម្បីបែងចែកថវិកាសារជាថ្មី] ផងដែរ។"*

## *ការផ្តល់សម្ភារៈបើធៀបនឹងការផ្តល់ថវិកាជាសាច់ប្រាក់*

ការរំពឹងទុកក្នុងគោលការណ៍ណែនាំស្តីពីមជ្ឈមណ្ឌលសិក្សាសហគមន៍ គឺអ្នកគ្រប់គ្រងមជ្ឈមណ្ឌលទទួលបានថវិកាជាសាច់ប្រាក់ដើម្បីប្រើឱ្យស្របទៅតាមសកម្មភាពដែលបានគ្រោងទុក។ ប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ជាច្រើនបានរាយការណ៍ថាពួកគេទទួលសម្ភារៈដោយផ្ទាល់ពីមន្ទីរអប់រំខេត្ត ឬការិយាល័យអប់រំស្រុកជំនួសឱ្យការទិញសម្ភារៈដោយខ្លួនឯង។ សម្រង់សម្តីខាងក្រោមបង្ហាញ ពីបញ្ហានៃភាពជាម្ចាស់របស់ភាគីពាក់ព័ន្ធផ្សេងៗ។

មន្ទីរអប់រំខេត្តលេខ១៖ *"តាំងពីឆ្នាំ២០១៣ មន្ទីរអប់រំខេត្តបានទិញសម្ភារៈសម្រាប់បណ្តុះបណ្តាលក្នុងនាមឱ្យម.ស.ស។ សម្រាប់ប្រាក់បៀវត្សគ្រូជំនាញ យើងក៏ត្រូវការហត្ថលេខាពីការិយាល័យអប់រំស្រុកដែរ។"*

មន្ទីរអប់រំខេត្តលេខ២៖ *"ខ្ញុំមិនសូវសប្បាយចិត្តលើការចំណាយទេពីព្រោះ ម.ស.ស មិនត្រូវបានអនុញ្ញាតអោយគ្រប់គ្រងថវិការបស់ពួកគេទេ។ ខ្ញុំចង់ឱ្យពួកគេគ្រប់គ្រង ថវិកាផ្ទាល់ខ្លួន។ សព្វថ្ងៃនេះ ការិយាល័យអប់រំស្រុកបានទិញសម្ភារៈសម្រាប់ម.ស.ស។ ខ្ញុំគិតថាពួកគេបានធ្វើចឹងដោយសារប្រហែលជាពួកគេមិនទុកចិត្តសមត្ថភាពរបស់ម.ស.ស។ ពួកគេប្រហែលជាបារម្ភថាម.ស.សចំណាយប្រាក់លើខុសខ្នង់ថវិកា។"*

*ម.ស.ស៥.២ "ខ្ញុំមិនដឹងថាថវិកាប៉ុន្មានដែលក្រសួងបានអនុម័តឱ្យម.ស.សរបស់ខ្ញុំទេ ឆ្នាំនេះពីព្រោះនៅខែឧសភា ខ្ញុំគ្រាន់តែបានទទួលសម្ភារៈបង្រៀនដូចជាក្រណាត់៣០ម៉ែត្រ សៀវភៅទស្សនាវដ្តីម៉ូតូរ៉ូបមួយចំនួន ផ្ទាំងអ៊ុត [ពីការិយាល័យអប់រំខេត្ត]ប៉ុណ្ណោះ។"*

តារាងខាងក្រោមបង្ហាញពីម.ស.សពីខេត្ត៣ក្នុងចំណោម៥ខេត្ត ដែលបានទទួលសម្ភារៈដោយផ្ទាល់ពីការិយាល័យអប់រំស្រុក ឬមន្ទីរអប់រំខេត្ត




*រូបភាព៧៖ ចំនួនម.ស.សដែលទទួលបានថវិកា ឬសម្ភារៈឆ្នាំ២០១៤ រហូតដល់ ខែវិច្ឆិកា*

ក្នុងខេត្តលេខ១ ប្រធានម.ស.សបានរៀបរាប់ថាបានទទួលសម្ភារៈ ប៉ុន្តែក្នុងការសន្ទនាបន្ថែមទៀត វាកាន់តែប្រាកដថាពួកគេសំដៅទៅលើសម្ភារៈដែលបាន ទទួលការពីឆ្នាំមុន ដែលពួកគេអាចប្រើបានចំពោះសកម្មភាពឆ្នាំ២០១៤ ហើយដែលពួកគេមិនបានទទួល សម្ភារៈថ្មីៗ ឬថវិកាក្នុងឆ្នាំ២០១៤ នៅចំពេលនៃការសិក្សានេះទេ។

បញ្ហានៃភាពជាម្ចាស់នៃថវិការបស់ម.ស.ស ក៏ត្រូវបានលើកឡើងក្នុងការពិភាក្សាក្រុមជាមួយគ្រូជំនាញដែរ។ គ្រូជំនាញបានបញ្ជាក់ហើយបញ្ជាក់ទៀតថាសម្ភារៈឬម៉ាស៊ីនត្រូវបានបញ្ជូនឱ្យមកម.ស.សរបស់ពួកគេដោយផ្ទាល់។ ម.ស.សនិងគ្រូជំនាញមិនត្រូវបានពាក់ព័ន្ធនឹងការទិញទេ។ ដោយហេតុថាផែនការត្រូវបានរៀបចំដោយមន្ទីរអប់រំខេត្តជាជាងម.ស.ស ការទិញសម្ភារៈដោយការិយាល័យអប់រំ ស្រុក ឬមន្ទីរអប់រំខេត្ត ជាញឹបញញាប់មិនបានឆ្លើយតបនឹងតម្រូវការពិតប្រាកដរបស់វគ្គសិក្សាទេ។

> គ្រូជំនាញ១.១.៤ ក្នុងកិច្ចពិភាក្សាក្រុមបាននិយាយថា៖ *"មន្ទីរអប់រំខេត្តបានទូរស័ព្ទមកខ្ញុំឱ្យមកយកសម្ភារៈ ប៉ុន្តែខ្ញុំមិនដែលបានស្នើរបស់ទាំងនោះទេ។ សម្ភារៈមួយ ចំនួនក្នុងនោះ ខ្ញុំមិនត្រូវការផង។"*

ទម្លាប់នៃការទិញសម្ភារៈនេះមិនស្របតាមគោលការណ៍ណែនាំស្តីពីមជ្ឈមណ្ឌលសិក្សាសហគមន៍ទេដែលថាម.ស.សមានតួនាទីក្នុងការគ្រប់គ្រងសម្ភារៈនិងថវិកា។

បញ្ហាភាពជាម្ចាស់ក្នុងការទិញសម្ភារៈក៏មានផលប៉ះពាល់ដល់ប្រតិបត្តិការរបស់ម.ស.សដែរ។ គ្រូជំនាញបានត្អូញត្អែរពីសម្ភារៈ និងឧបករណ៍បង្រៀនដែលមានគុណភាពអន់ (ម៉ាស៊ីន ដេរ ត្រង់ជីស្ស កាត់សក់ជាដើម)។ បន្ថែមពីនេះទៅទៀត សម្ភារៈដែលបានឱ្យជានិច្ចកាលខុសពីតម្រូវការរបស់គ្រូជំនាញ។ គ្រូជំនាញបានរៀបរាប់ថាវត្តមានរបស់សិស្សបានត្រូវ ប៉ះពាល់ដោយការដែលខ្វះសម្ភារៈបង្រៀន។ បើសិនគ្មានឧបករណ៍សម្រាប់អនុវត្តទេ សិស្សមិនបានរៀនទេ ហើយជាលទ្ធផលពួកគេឈប់មករៀនតែម្តង។

> គ្រូជំនាញ ១.២ *"ម៉ាស៊ីនដេរដែលខ្ញុំទទួលបាន [ពីថ្នាក់មុន] មិនដំណើរការល្អទេ ខ្ញុំត្រូវខំប្រឹងយ៉ាងលំបាកដើម្បីជួសជុលវា ទោះយ៉ាងណាក្តីក៏ម៉ាស៊ីននៅតែមិន ដើរស្រួលដដែល។ ខ្ញុំក៏សំណូមពរយកម៉ាកដែលមានគុណភាពល្អ ម៉ាកពីជប៉ុនដែល ខ្ញុំប្រើនៅឯតូបគឺមានគុណភាពល្អ។"*

> គ្រូជំនាញ១.៣ *"សិស្សជាច្រើនគ្រាន់តែធ្វើត្រាប់តាមខ្ញុំដោយកាន់ឧបករណ៍ក្នុងការរៀនកាត់សក់គ្រាន់តែធ្វើតាមខ្ញុំ។ អ្នករៀនខ្លះបានឈប់ពីព្រោះពួកយើងមិនមានឧបករណ៍ ឬសម្ភារៈដើម្បីឱ្យពួកគេរៀន។"*

គ្រូជំនាញបានសម្តែងនូវភាពមិនពេញចិត្តជាខ្លាំងលើសម្ភារៈ ឬឧបករណ៍ដែលផ្តល់ឱ្យ និងបំណងប្រាថ្នាចង់រកសម្ភារៈទាំងនេះដោយខ្លួនឯងដោយប្រើប្រាស់ថវិកាដែលបែងចែកឱ្យ។

## *ភាពទាន់ពេលវេលា និងភាពញឹកញាប់នៃការតម្លាក់ថវិកា*

បន្ថែមពីលើបញ្ហាដែលជាប់ទាក់ទងនឹងថវិកាប៉ុន្មានដែលបានបែងចែកអោយម.ស.ស ការសិក្សានេះរកឃើញផងដែរពីបញ្ហាដ៏សំខាន់ពាក់ព័ន្ធនឹងការពន្យាពេលនៃការទម្លាក់ថវិកានៅថ្នាក់មូលដ្ឋានសម្រាប់តំបន់ ទាំងនោះពិតជាបានចែកចាយថវិកាជាសាច់ប្រាក់ទៅម.ស.ស ហើយជាការទូទាត់ប្រាក់បៀវត្សឱ្យគ្រូជំនាញ។

មន្ទីរអប់រំខេត្ត៤បានប្រាប់ថាផ្នាំការចំណាយថវិកាសម្រាប់ឆ្នាំ២០១៤ សម្រាប់គំរោងអប់រំក្រៅប្រព័ន្ធគឺត្រូវធ្វើជា៤ដំណាក់កាលទៅរតនាគារខេត្ត ហើយបន្ទាប់មកទៅមន្ទីរអប់រំខេត្ត។ មានតែខេត្តមួយក្នុងចំណោមខេត្តទាំងនេះទេ ដែលធ្វើជាការចំណាយ៤ទៅកាន់កម្រិតការិយាល័យស្រុក ឬម.ស.ស។ ខេត្ត៣ផ្សេងទៀតបានបែងចែកការចំណាយមួយចំណែកទៅកម្រិតការិយាល័យអប់រំស្រុកឬម.ស.ស ប៉ុន្តែវាមិនអាចទៅរួចក្នុងការពិនិត្យកស្តុតាងនៃចំនួនសរុបដែលត្រូវបានចំណាយ។ តារាងខាងក្រោមតំណាងឱ្យចំនួនដងនៃការទម្លាក់ថវិកាទៅឱ្យមន្ទីរអប់រំខេត្ត និងម.ស.ស។

| ខេត្ត | ការផ្ទេរហិរញ្ញវត្ថុ | |
|---|---|---|
| | ទៅកម្រិត មន្ទីរអប់រំខេត្ត | ទៅកម្រិត ម.ស.ស |
| ខេត្តលេខ១ | N/A | |
| ខេត្តលេខ២ | 4 | 1 |
| ខេត្តលេខ៣ | 3 | 1 |
| ខេត្តលេខ៤ | 2 | 2 |
| ខេត្តលេខ៥ | 4 | 4 |

*តារាង៤៖ ការចំណាយថវិការបស់មន្ទីរអប់រំខេត្ត និងការិយាល័អប់រំស្រុក*

មន្ទីរអប់រំខេត្តក្នុងខេត្តលេខ១ បានរាយការណ៍ថាពួកគេមិនបានទទួលការផ្ទេរថវិកាណាមួយទេពីមូលនិធិមជ្ឈមណ្ឌល/ការអប់រំក្រៅប្រព័ន្ធពីរតនាគារខេត្តកន្លងមក ប៉ុន្តែពួកគេគ្រាន់តែបានទទួលសំណើឱ្យប្រមូលការបង់ប្រាក់ដំបូងក្នុងឆ្នាំ។ អ្នកផ្តល់សម្ភាសន៍មិនបានដឹងថាថវិកាប៉ុន្មានពួកគេអាចនឹងទទួលបានពីការបង់ប្រាក់ដំបូងនេះទេ។

ក្នុងចំណោមខេត្ត៥ដែលត្រូវបានសិក្សា មន្ទីរអប់រំខេត្តចំនួន៣បានទទួលការទម្លាក់ថវិកាទាំងអស់នៃថវិការបស់ម.ស.សមុនពេលការសិក្សានេះចាប់ផ្តើមក្នុងខេត្តវិច្ឆិកា។ ខេត្តមួយបានរាយការណ៍ថា ម.ស.សរបស់ពួកគេបានទទួលថវិកាគាំទ្រចំនួនប្រហែល១៣%នៃថវិកាដែលបានអនុម័តសម្រាប់ឆ្នាំ២០១៤ រួចហើយ។

ជាទូទៅបញ្ហាមួយចំនួនជុំវិញការទម្លាក់ ថវិកាយឺតយ៉ាវបានលេចឡើងច្បាស់នៅគ្រប់កម្រិតទាំងអស់។៥២%នៃមជ្ឈមណ្ឌលសិក្សាសហគមន៍បាននិយាយថាពួកគេមិនបានទទួលការទម្លាក់ថវិកាពីការិយាល័យអប់រំស្រុកមកដល់ខែវិច្ឆិកានេះទេ ។ ៤៣%បានទទួលថវិកាខ្លះប៉ុន្តែការទម្លាក់គឺយឺតយ៉ាវហើយ ពួកគេទើបតែបានទទួលក្នុងខែកក្កដា សីហា ឬកញ្ញានេះទេ។ មានតែម.ស.ស មួយតែប៉ុណ្ណោះ ដែលស្ថិតក្នុងបរិវេណការិយាល័យរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានប្រាប់ថាបានទទួលថវិកាជារៀងរាល់ខែ។ និន្នាការរួមនៃការទម្លាក់ថវិកាយឺត ទៅអោយមជ្ឈមណ្ឌលត្រូវបានបង្ហាញក្នុងតារាងខាងក្រោម។




*រូបភាព៨៖ ភាគរយនៃម.ស.សដែលបានទទួលឬមិនទទួលថវិការហូតមកដល់ខែវិច្ឆិកា ឆ្នាំ២០១៤ បើយោងតាមប្រធានម.ស.ស*

ការពន្យាពេលនេះបានប៉ះពាល់ដល់ការទូទាត់ដោយផ្ទាល់នៃប្រាក់ខែគ្រូជំនាញផងដែរ។ ៩១%នៃគ្រូជំនាញបានរាយការណ៍ថាពួកគេបានទទួលប្រាក់បៀវត្សរបស់ពួកគេយឺតខ្លាំងជានិច្ចកាលពីរឬបីខែក្រោយវគ្គបានបញ្ចប់។ ក្នុងការពិភាក្សាក្រុម គ្រូជំនាញបាននិយាយថា ពួកគេត្រូវរងចាំរហូតដល់ខែធ្នូ ឬយូរជាងនេះមុនទទួលបានប្រាក់ខែ។

ការពិភាក្សាក្រុម១.២ *"ខ្ញុំបានបញ្ចប់វគ្គសិក្សាក្នុងខែកញ្ញា ប៉ុន្តែខ្ញុំត្រូវរងចាំបើកប្រាក់ខែ ដែលពេលខ្លះរហូតដល់ខែមករាឆ្នាំក្រោយ..."*។




*រូបភាព៩ បង្ហាញពីការពន្យាប្រាក់ខែសម្រាប់គ្រូជំនាញនៅម.ស.ស ដែលបានទៅធ្វើទស្សនកិច្ច*

ការអនុវត្តន៍នេះខុសគ្នាពីគោលការណ៍ណែនាំផ្សេងៗពីម.ស.ស ដែលបានចែងថាគ្រូជំនាញគួរបានទទួលប្រាក់ខែជារៀងរាល់ខែ។ ប្រាក់ខែដែលត្រូវបានពន្យាបានធ្វើឱ្យគ្រូជំនាញយ៉ាងហោចណាស់ ៣នាក់ត្រូវខ្ចីលុយ (ជាការបើកប្រាក់ខែឲ្យមុន) ពីប្រធានម.ស.ស ការិយាល័យអប់រំស្រុក ឬគណនីយ្យកររបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ហើយសងវិញនៅពេលដែលពួកគេទទួលបានប្រាក់ខែ។ អ្នកផ្តល់សម្ភាសន៍បានបញ្ជាក់ថាការអនុវត្តន៍នេះជារឿងធម្មតាដូចខាងក្រោម៖

*ម.ស.ស១.៣ "ខណៈពេលដែលរង់ចាំប្រាក់ខែរបស់ពួកគេ គ្រូជំនាញបានបើកប្រាក់ជំនួសមុនពីគណនេយ្យកររបស់មន្ទីរអប់រំខេត្ត។"*

ការិយាល័យអប់រំស្រុក៣.១ *"...ការខ្ចីលុយពីគណនីយ្យករជាការទាក់ទងផ្ទាល់ខ្លួនមួយក្រៅប្រព័ន្ធ... វាជារឿងផ្ទាល់ខ្លួនបុគ្គល។ ប៉ុន្តែនៅពេលប្រាក់ខែអាចបើកបាន គណនេយ្យករនឹងបើកប្រាក់ខែយកជំនួសវិញ (រួមទាំងការប្រាក់)។"*

បញ្ហាផ្សេងដែលលេចឡើងពីការសម្ភាសន៍គឺភាពខុសគ្នារវាងប្រាក់ខែគ្រូជំនាញបានទទួលនិងអ្វីដែលពួកគេត្រូវបានរំពឹងថាទទួលបានដូចដែលការណែនាំបានបញ្ជាក់។ បើទោះជាគ្រូជំនាញខ្លះជឿថា នេះក្លាយជាប្រាក់រួមចំណែកដល់ការគ្រប់គ្រងម.ស.ស (ជាពិសេសដល់ប្រធាន) គ្រូជំនាញខ្លះដែលបានបង្ហើបថាមូលហេតុនៃការបន្ថយមិនត្រូវបានប្រាប់អោយដឹងទេ។

*ការពិភាក្សាក្រុម២.១ "...ខ្ញុំទទួលបានតែ៣០០០០០រៀលមួយខែតែប៉ុណ្ណោះ ពីព្រោះខ្ញុំចាំបាច់ត្រូវឱ្យ៦០០០០រៀលទៅប្រធានមជ្ឈមណ្ឌល"*

## *ផលប៉ះពាល់នៃការទម្លាក់ថវិកាយឺតយ៉ាវ និងការទូទាត់ប្រាក់ខែយឺតយ៉ាវ*

គ្រូជំនាញជាច្រើនបានរកឃើញនូវផលប៉ះពាល់មួយចំនួនពីការទម្លាក់ថវិកាយឺតមកម.ស.សរបស់ពួកគេ។ ផលប៉ះពាល់ដែលលើកឡើងញឹកញាប់ជាងគេគឺប៉ះពាល់ដល់វត្តមានអ្នកសិក្សា តួយ៉ាងដូចអ្នកសិក្សាខ្លះអស់ជំនឿលើវគ្គបណ្តុះបណ្តាល ដោយសារកង្វះសម្ភារៈដើម្បីអនុវត្ត និងដោយសារការបង្រៀនហាក់មានលក្ខណៈទ្រឹស្តីជាជាងការអនុវត្តជាក់ស្តែង។ ផលប៉ះពាល់ផ្សេងទៀតសំខាន់ដែលលើកឡើងដោយគ្រូជំនាញដែរនោះគឺការពន្យារវគ្គពេលបណ្តុះបណ្តាលរហូតដល់ថវិកា ឬសម្ភារៈធ្លាក់មកដល់។

គ្រូជំនាញមួយក្រុមបាននិយាយថា៖ *"គ្មានសិស្សណាម្នាក់ចង់មករៀនវគ្គបណ្តុះបណ្តាលទេ។ ពួកគេយល់ថាគ្មានប្រយោជន៍ក្រោយពេលពួកគេបានសាកល្បងរៀនដោយគ្មានសម្ភារៈដើម្បីបង្ហាញដល់សិស្ស។"*

ការទម្លាក់ថវិកាយឺតយ៉ាវជះឥទ្ធិពលដល់ម.ស.សជាច្រើនផ្នែក រួមមាន៖

- គ្រូជំនាញបានរាយការណ៍ថាបានបាត់បង់កម្លាំងចិត្តនៅពេលដែលពួកគេមិនបានទទួលថវិកាជាទៀងទាត់។
- ការប្រើប្រាក់ផ្ទាល់ខ្លួនរបស់ម.ស.សឬគ្រូជំនាញដើម្បីទិញសម្ភារៈក្នុងការធ្វើអោយប្រាកដថាវគ្គចាប់ដំណើរការទាន់ពេលវេលា។
- ការបង្រៀនមានតែក្នុងទ្រឹស្តីខណៈពេលដែលរង់ចាំសម្ភារៈសម្រាប់ការអនុវត្តក្នុងថ្នាក់។
- ថ្នាក់សិក្សាត្រូវបានផ្អាក ពន្យាពេល ឬពង្រួញដើម្បីឱ្យសមស្របតាមភាពទំនេររបស់អ្នកសិក្សាមុនពេលរដូវប្រមូលផលមកដល់។
- ការចាប់ផ្តើមថ្នាក់យឺត (ប្រហែលខែឧសភា) បង្កអោយត្រូវពន្យាកម្មវិធីរហូតដល់ ខែតុលា ឬវិច្ឆិកា។ ជាលទ្ធផល សិស្សជាច្រើនឈប់សិក្សាមុនពេលវគ្គត្រូវបានបញ្ចប់នៅពេលដែលពួកគេត្រូវជួយក្រុមគ្រួសារក្នុងការប្រមូលផល។




*រូបភាព ១០៖ ផលប៉ះពាល់ដែលបានរៀបរាប់ពីការតម្លាក់ថវិកាមកកាន់ម.ស.សយឺតយ៉ាវ*

## *មូលហេតុនៃការពន្យាពេលទម្លាក់ថវិកា*

ការពន្យាពេលទម្លាក់ថវិកាកើតឡើងនៅគ្រប់កម្រិត។ ការសិក្សាបានរកឃើញពីមូលហេតុខុសៗគ្នា ដែលអាចរួមចំណែកដល់ការផ្ទេរថវិកាយឺត។

## *ការងាររៀបចំឯកសារហិរញ្ញវត្ថុ (ការទូទាត់វិក័យបត្រ)*

ការរៀបចំឯកសារទូទាត់ថវិកាត្រូវបានរៀបរាប់ថាមានលក្ខណៈស្មុគស្មាញ និងត្រូវការសមត្ថភាព ពេលវេលានិងភាពយកចិត្តទុកដាក់។ អ្នកផ្តល់បទសម្ភាសន៍ក្នុងការសិក្សានេះនៅគ្រប់កម្រិតបាននិយាយថាពួកគេចាំបាច់ត្រូវបំពេញទម្រង់ជាច្រើនដើម្បីទទួលបានថវិកា។ ដំណើរការនៃការផ្ទេរប្រាក់ត្រូវការឯកសារទូទាត់ថវិកា (ឧទាហរណ៍ វិក័យបត្រ) ពីឆ្នាំមុនឬដំណាក់កាលមុននៃការផ្ទេរប្រាក់។ ម.ស.ស ត្រូវបានសួរឱ្យប្រគល់ឯកសារ ទូទាត់ថវិកាទៅឱ្យការិយាល័យអប់រំស្រុក ហើយការិយាល័យអប់រំស្រុកបន្ទាប់មកបង្រួមឯកសាររួចប្រគល់ជូនមន្ទីរអប់រំមុនពេលមន្ទីរអប់រំប្រគល់ឯកសារទូទាត់ថវិកា ដែលបានបង្រួមរួចទៅរតនាគារខេត្ត និងនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ។

ការងាររៀបចំឯកសារនេះជានិច្ចកាលត្រូវបានពន្យាពេល ពីព្រោះការប្រមូលឯកសារទូទាត់ថវិកាពីគ្រប់ម.ស.សត្រូវការពេលវេលាយូរសម្រាប់ការិយាល័យអប់រំស្រុក។ ការពន្យាពេលកើតឡើងម្តងទៀតនៅឯមន្ទីរអប់រំខេត្ត នៅពេលគណនីយ្យករត្រូវរង់ចាំគ្រប់ឯកសារពីការិយាល័យអប់រំស្រុកមុនពេលបង្រួម និងប្រគល់ទៅឱ្យរតនាគារខេត្ត។ បទសម្ភាសន៍មួយជាមួយមន្ត្រីមកពីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធបានបង្ហាញពីការយល់ឃើញដូចគ្នាថា៖

មន្ទីរអប់រំខេត្តលេខ៣៖ *"ការទម្លាក់ថវិកាត្រូវបានពន្យាពីព្រោះមានទម្រង់ជាច្រើនដែលយើងត្រូវបំពេញ និងត្រូវពិនិត្យនិងអនុម័តដោយអ្នកពាក់ព័ន្ធជាច្រើន។*

មន្ទីរអប់រំខេត្តលេខ១៖ *"ម.ស.សខ្លះមិនទាន់បានប្រគល់របាយការណ៍ហិរញ្ញវត្ថុនៅឡើយ ម.ស.សផ្សេងទៀតបានប្រគល់របាយការណ៍របស់គេទៅការិយាល័យអប់រំចប់សព្វគ្រប់ ហើយពួកគេក៏បានបញ្ជូនទៅមន្ទីរអប់រំខេត្ត ដូច្នេះគណនីយ្យករមិនអាចផ្ទេរហិរញ្ញវត្ថុថ្មីទេ... វាយឺតពេលពីព្រោះខេត្តយើងបានប្រគល់ផែនការរួចហើយ ប៉ុន្តែនាយកដ្ឋានអប់រំក្រៅប្រព័ន្ធត្រូវរង់ចាំខេត្តផ្សេងៗទៀតដើម្បីប្រគល់ផែនការរបស់ពួកគេមុនពេលអនុម័តផែនការ។ នេះជាមូលហេតុដែលការទម្លាក់ថវិកាត្រូវពន្យាពេលនិងប៉ះពាល់ដល់គ្រប់ម.ស.ស។"*

ការពិភាក្សាក្រុម១.១ បានបង្ហាញថា *"ខ្ញុំទទួលបានប្រាក់ខែយ៉ាងយឺតបំផុតក្នុងខែ វិច្ឆិកាពីព្រោះការិយាល័យអប់រំស្រុកបានបង្រួមនិងប្រគល់វិក័យបត្រដែលបានទូទាត់ទៅមន្ទីរអប់រំយឺត។"*

រតនាគារខេត្តលេខ៣ *"ពួកយើងមិនទាន់បានទម្លាក់ថវិកាជុំទី៤នៅឡើយពីព្រោះពួកគេ (មន្ទីរអប់រំ ខេត្ត) មិនទាន់បានប្រគល់ទម្រង់ទូទាត់រួចសម្រាប់ជុំទី៣នៅឡើយទេ"។*

## *ពេលវេលា និងចម្ងាយ*

ពេលវេលានិងចម្ងាយប្រហែលជាអាចរួមចំណែកដល់ការទម្លាក់ថវិកាយឺតដែរ។ ចម្ងាយពីម.ស.សខ្លះទៅការិយាល័យស្រុកឬមន្ទីរអប់រំខេត្តបានជះឥទ្ធិពលដល់ដំណើរការទម្លាក់ថវិកា។ ធ្វើដំណើរទៅកាន់ការិយាល័យមួយៗទាមទារពេលវេលា និងថ្លៃធ្វើដំណើរ។ វាបានលេចឡើងពីការសិក្សានេះថាក្នុងករណីខ្លះ ប្រធានម.ស.ស ឬគ្រូជំនាញត្រូវធ្វើដំណើរទៅមន្ទីរអប់រំខេត្តដើម្បីបើកប្រាក់ខែរបស់ពួកគេ។ មន្ត្រីមន្ទីរអប់រំខេត្តម្នាក់បានរៀបរាប់ថាការិយាល័យអប់រំស្រុកត្រូវសាកល្បងជាច្រើនលើក ដើម្បីបានជួបគណនីយ្យករ របស់មន្ទីរអប់រំខេត្ត ដូច្នេះត្រូវចំណាយប្រាក់ផ្ទាល់ខ្លួនក្នុងការធ្វើដំណើរជាច្រើនដង។ ផ្ទុយទៅវិញមន្ត្រីមន្ទីរអប់រំខេត្តម្នាក់ទៀតបាននិយាយថាគាត់ត្រូវទូរស័ព្ទទៅមន្ត្រីការិយាល័យអប់រំដើម្បីមកបើកប្រាក់ពីការិយាល័មន្ទីរអប់រំខេត្ត។

មន្ទីរអប់រំខេត្ត *"ខ្ញុំត្រូវរង់ចាំឯកសារទូទាត់ថវិកាពីការិយាល័យអប់រំស្រុកទាំងអស់ដើម្បីស្នើ/ផ្ទេរថវិកា(សម្រាប់ជុំមួយទៀត)ពីព្រោះវាសន្សំសំចៃពេលវេលា។ ខ្ញុំត្រូវការប្រាក់ធ្វើដំណើរ និងចុះបេសកកម្មដើម្បីប្រមូលឯកសារឱ្យបានលឿន [តាមរយៈធ្វើដំណើរទៅកាន់ការិយាល័យអប់រំស្រុក/ម.ស.ស]។"*

*មន្ទីរអប់រំខេត្តលេខ២ "...ការិយាល័យអប់រំស្រុកខ្លះបានមកជាច្រើនលើកមុនពេល ទើបពួកគេអាចជួបគណនីយ្យកររបស់មន្ទីរអប់រំខេត្ត ឬប្រគល់ទម្រង់ដែលត្រឹមត្រូវ (ឬឯកសារ) ពួកគេត្រូវចំណាយពេលនិងលុយកាក់ច្រើនដើម្បីធ្វើដំណើរទៅមក...។"*

## ការពេញចិត្តរបស់ប្រធានម.ស.សលើដំណើរការទម្លាក់ថវិកា និងយោបល់កែលម្អ

៥៩%នៃប្រធានម.ស.សមិនពេញចិត្តនឹងដំណើរការទម្លាក់ថវិកានេះទេ។




*រូបភាព១១៖ ការពេញចិត្តរបស់ប្រធានម.ស.សលើការអនុវត្តនៃការទម្លាក់ថវិកា*

យោបល់ខាងក្រោមនេះដែលបានមកពីកម្រិតខុសៗគ្នាបានលេចចេញក្នុងការសិក្សានេះ។

៥០%នៃប្រធានម.ស.សបានស្នើសុំទម្លាក់ថវិកាដោយផ្ទាល់ពីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធទៅកាន់ម.ស.សតែម្តងតាមប្រព័ន្ធធនាគារដូចជា ប្រព័ន្ធអេធីអុឹម (ATMs)។ បន្ថែមពីនេះទៀតពួកគេសំណូមពរថាថវិកាទាំងមូលគួរត្រូវបានទម្លាក់តាំងពីដើមឆ្នាំ ឬយ៉ាងហោចណាស់មុនពេលការបណ្តុះបណ្តាលចាប់ផ្តើម។ស្រដៀងគ្នានេះដែរប្រហែលជាជិតពាក់កណ្តាលនៃគ្រូជំនាញមុខរបរក៏គាំទ្រនូវសំណូមពរនេះដែរ។ គួរឱ្យចាប់អារម្មណ៍ ៩០%នៃការិយាល័យអប់រំស្រុកក៏បានគាំទ្រសំណូមពរនេះ ហើយបានបន្ថែមថាការិយាធិបតេយ្យដ៏យូរក្នុងដំណើរការទម្លាក់ថវិកាគួរត្រូវបានកាត់បន្ថយ។ ៤ក្នុងចំណោម៥មន្ទីរអប់រំ ខេត្តក៏គាំទ្រសំណូមពរនេះដើម្បីឱ្យការទម្លាក់ថវិកាមានប្រសិទ្ធភាពជាងមុន។

គ្រូជំនាញដែលផ្តល់បទសម្ភាសន៍ជាងច្រើនជាង៥០% បានស្នើសុំថាប្រាក់ខែរបស់គេគួរទូទាត់ប្រចាំខែ។ ប្រធានម.ស.ស៨នាក់ក្នុងចំណោម២១នាក់បានស្នើសុំប្រាក់ខែ ឬប្រាក់ឧបត្ថម្ភសម្រាប់ការបំពេញតួនាទីរបស់ពួកគេ។ ជាមួយនឹងការទម្លាក់ថវិកា ការធ្វើផែនការប្រកបដោយប្រសិទ្ធិភាពជាការចាំបាច់។ ដើម្បីកែលម្អការធ្វើផែនការ ម.ស.សសំណូមពរឱ្យមានការគាំទ្រដូចជាបរិក្ខារការិយាល័យ ដូចជាកុំព្យូទ័រជាដើម។

## *ការធ្វើផែនការថវិកា*

មន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក និងប្រធានម.ស.សភាគច្រើនសម្តែងនូវឆន្ទៈក្នុងការសម្លឹងមើលធ្វើផែនការថវិកាចាប់ផ្តើមពីថ្នាក់មូលដ្ឋានទៅ។ ក្នុងករណីជាច្រើន សមត្ថភាពរបស់ប្រធានម.ស.សក្នុងការធ្វើផែនការថវិកាត្រូវបានមន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុកនិយាយថា នៅមានកម្រិត បើទោះជាប្រធានម.ស.សភាគច្រើនមិនគិតដូច្នោះក៏ដោយ។ សំណូមពររួមមាន៖

- ពង្រឹងសមត្ថភាពរបស់ប្រធានម.ស.សលើការធ្វើផែនការថវិកា (៤ ទៅ ៥វគ្គ) ជាមួយនឹងជំនួយបន្ថែមក្នុងការធ្វើការងារនេះ។
- ព័ត៌មានច្បាស់លាស់លើតម្រូវការទាក់ទងការរៀបចំផែនការពីក្រសួងអប់រំ យុវជន និងកីឡាជាមុន។ ការធ្វើផែនការនិងពេលវេលាគួរត្រូវបានតម្រង់ទិសដោយការិយាល័យអប់រំស្រុក និងមជ្ឈមណ្ឌលសិក្សាសហគមន៍។
- កាត់បន្ថយការលៃតម្រូវនៅថ្នាក់ក្រសួងដើម្បីឱ្យខេត្តទទួលបានថវិកាដែលប្រហាក់ប្រហែលនឹងចំនួនដែលបានសំណូមពរ។
- បញ្ចូលភាគីពាក់ព័ន្ធក្នុងការធ្វើផែនការថវិកានិងសកម្មភាពដើម្បីឱ្យពួកគេបញ្ចូលនូវតម្រូវការរបស់សហគមន៍។
- ធ្វើឱ្យមានការប្រកាន់ខ្ជាប់ទៅការណែនាំផ្សេងៗក្នុងគោលការណ៍ណែនាំក្រសួងនៅគ្រប់កម្រិត។

## *ការស្នើសុំហិរញ្ញវត្ថុ*

ដូចដែលបានបញ្ជាក់រួចមកហើយថាការទម្លាក់ថវិកាគឺមានភាពយឺតយ៉ាវចាប់ពីកម្រិតមន្ទីរអប់រំខេត្តដែលធ្វើឱ្យប៉ះពាល់នាំមកនូវការចំណាយពេលវេលាយូរ។ ដើម្បីធ្វើឱ្យដំណើរការទម្លាក់ថវិកា មានប្រសិទ្ធភាពជាងមុន មន្ទីរអប់រំ និងប្រធានម.ស.សស្នើដូចខាងក្រោម៖

- ពន្លឿនល្បឿននៃការទម្លាក់មកកាន់កម្រិតមន្ទីរអប់រំខេត្តដើម្បីធ្វើឱ្យប្រាកដថាមន្ទីរអប់រំខេត្តមានប្រាក់ ក្នុងការអនុវត្តន៍សកម្មភាពរបស់ពួកគេឱ្យទាន់ពេលវេលា។
- ទូទាត់ប្រាក់មុនពេលផែនការត្រូវបានអនុម័ត ជាជាងក្រោយពេលផែនការត្រូវបានអនុម័ត។
- ការចូលរួមដ៏សកម្មពីគ្រប់កម្រិតក្នុងការផ្តល់ឯកសារនិងសេចក្តីអនុញ្ញាតឱ្យទាន់ពេលវេលា។
- វាគួរតែមានការស្នើសុំ និងការទម្លាក់ថវិកាតែម្តងក្នុងមួយឆ្នាំ។
- ការបែងចែកថវិកាអោយម.ស.សនីមួយៗគួរត្រូវបានបង្កើន។
- ការផ្ទេរប្រាក់តាមធនាគារ ឬប្រព័ន្ធអេជីអឹមគួរត្រូវបានប្រើក្នុងការផ្ទេរប្រាក់ទៅកាន់ម.ស.ស។

## *ការចំណាយថវិកា*

ប្រធានម.ស.សទាំងឡាយបានរៀបរាប់ពីបទពិសោធន៍របស់ពួកគេជុំវិញកង្វះជំនួយមូលនិធិសម្រាប់របស់ជាក់លាក់មួយចំនួន ខណៈដែលរបស់របរខ្លះត្រូវបានផ្តល់លើសពីតម្រូវការ។ សំណូមពររបស់ពួកគេរួមមានដូចខាងក្រោមៈ

- ការផ្តល់កញ្ចប់ប្រាក់បៀវត្សដល់ប្រធានម.ស.ស។
- អនុញ្ញាតអោយប្រធានម.ស.សលៃតម្រូវការចំណាយលើខ្ទង់ចំណាយមួយចំនួន (ខ្ទង់ចំណាយឆ្លង) ដែលឆ្លុះបញ្ចាំងពីតម្រូវការជាក់ស្តែង។
- តម្លើងប្រាក់បៀវត្សគ្រូជំនាញដោយបញ្ចូលកញ្ចប់អត្ថប្រយោជន៍ខ្លះៗដែលស្រដៀងនឹងគ្រូបឋមសិក្សា។
- ការចែកចាយរបាយការណ៍ហិរញ្ញវត្ថុឱ្យមានតម្លាភាពជាមួយម.ស.សដោយបង្ហាញពីការចំណាយលើការអប់រំក្រៅប្រព័ន្ធរបស់ការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត។
- រាល់ខ្ទង់ចំណាយគួរមានវិក័យបត្រដើម្បីបង្ហាញពីតម្លាភាព។
- ការចំណាយថវិកាដែលអនុញ្ញាតនៅកម្រិតម.ស.ស រួមជាមួយការតាមដាន និងការផ្តល់ការគាំទ្រនៅពេលដែលត្រូវការរបស់មន្ទីរអប់រំខេត្តនិងការិយាល័យអប់រំស្រុក

## V. សេចក្តីសន្និដ្ឋាន

ខណៈពេលដែលនេះជាការសិក្សាខ្នាតតូច វាអាចទៅរួចក្នុងការទទួលបានការយល់ដឹងយ៉ាងច្រើនពីទម្លាប់ជាក់ស្តែងលើការគ្រប់គ្រងហិរញ្ញវត្ថុមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលជាលទ្ធផលនៃការប្រមូលព័ត៌មាននៅខេត្តចំនួន៥។ លុះត្រាតែតំបន់ដែលត្រូវបានសិក្សាមានលក្ខណៈខុសគ្នាខ្លាំងទៅតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា វាអាចសន្មតបានថាទម្លាប់នៃការទម្លាក់ថវិកាទៅមជ្ឈមណ្ឌលសិក្សាសហគមន៍ គឺមិនមានទាំងប្រសិទ្ធភាព និងប្រសិទ្ធផល ហើយវាខុសប្លែកគ្នាក្នុងផ្នែកមួយចំនួនលើគោលការណ៍ណែនាំថ្នាក់ជាតិ។ នេះគឺជាលទ្ធផលនៃការប្រឈមលើសមត្ថភាព ប្រព័ន្ធ និងការកំណត់អាទិភាព។

មជ្ឈមណ្ឌលសិក្សាសហគមន៍ ការិយាល័យអប់រំស្រុក មន្ទីរអប់រំខេត្ត និងនាយកដ្ឋានអប់រំក្រៅប្រព័ន្ធគ្រប់គ្នាសុទ្ធតែជួបការប្រឈមមុខមួយចំនួនក្នុងការរៀបចំផែនការ ការបែងចែក និងការផ្ទេរថវិកាឱ្យបានត្រឹមត្រូវ ហើយការណ៍នេះត្រូវបានរៀបរាប់ថាបាននាំទៅរកការផ្តល់ការបណ្តុះបណ្តាលដែលមានគុណភាពអន់ជាងមុន ថ្នាក់ដែលមានរយៈពេលខ្លី ឬតូចជាង មុន និងការបោះបង់សិក្សារបស់សិស្សជា

ច្រើន។ បន្ថែមពីនេះទៅទៀត ក្នុងវិសាលភាពនៃការសិក្សានេះ ការអនុវត្តន៍ផ្ទុយគ្នាមានន័យថាវាមិនអាចទៅរួចក្នុងការតាមដានឱ្យបានត្រឹមត្រូវនូវការប្រើថវិកាម.ស.សដោយសារវាមិនត្រូវបានផ្ទេរទៅកាន់កម្រិតតាមបំណងជាថវិកាសាច់ប្រាក់។ វាមានឱកាសជាច្រើនដែលត្រូវបានរកឃើញក្នុងការអនុវត្តជាក់ស្តែងដែលអាចកំណង់បានជាការធ្វើខុសទិសដៅពីថវិកាដែលគម្រោងឱ្យមជ្ឈមណ្ឌលសិក្សាសហគមន៍។

ទាក់ទងនឹងសមត្ថភាពក្នុងការរៀបចំផែនការ វាមិនមានជាបញ្ហាប្រឈមធំដុំទេដែលលើកឡើងដោយភាគីពាក់ព័ន្ធនៅកម្រិតមន្ទីរអប់រំខេត្ត។ មន្ទីរអប់រំខេត្តខ្លួនឯងផ្ទាល់បានប្រាប់ពីកម្រិតល្អនៃទំនុកចិត្តដែលពួកគេមានលើជំនាញនៃការរៀបចំផែនការថវិការបស់ពួកគេ ប៉ុន្តែហាក់ចង់ត្អូញត្អែរពីសមត្ថភាពរបស់ការិយាល័យអប់រំស្រុកមួយចំនួន ជាពិសេសនៅស្រុកឆ្ងាយៗ និងជាកន្លែងដែលមានបុគ្គលិកឈប់ពីការងារខ្ពស់ផងដែរ។ ការិយាល័យអប់រំស្រុក និងប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ខ្លួនឯងផ្ទាល់បានប្រាប់ថាមានទំនុកចិត្តល្អក្នុងការរៀបចំផែនការប៉ុន្តែពួកគេមិនមានពេលវេលាធ្វើវា ឬមិនត្រូវបានស្នើដោយមន្ទីរអប់រំខេត្តឱ្យធ្វើវា។

បើទោះបីជាមានរបាយការណ៍ខ្លះៗពីម.ស.ស ការិយាល័យអប់រំស្រុក ឬមន្ទីរអប់រំខេត្ត រួមមានគ្រូជំនាញក្នុងការតាក់តែងសកម្មភាព ឱកាសក្នុងការចូលរួមក្នុងសហគមន៍ធំ ហាក់ត្រូវបានបំភ្លេច។ វាមានរូបភាពផ្សេងៗទាក់ទងនឹងការអនុវត្តន៍មុខងាររវាងម.ស.ស និងការិយាល័យអប់រំស្រុក ហើយជាលទ្ធផលកម្រិតផ្សេងចាប់យកតួនាទីក្នុងការរៀបចំផែនការថវិកា។ ប្រធានម.ស.សជាច្រើនសប្បាយចិត្តឱ្យអ្នកដទៃធ្វើការរៀបចំផែនការសកម្មភាព។ បើទោះបីជាគោលការណ៍ណែនាំថ្នាក់ជាតិចែងពីការរៀបចំផែនការពីកម្រិតក្រោមឡើងទៅកម្រិតលើយ៉ាងណាក៏ដោយ ការអនុវត្តន៍ជាក់ស្តែងបានបង្ហាញយ៉ាងច្បាស់ពី "កម្រិតពីលើមកក្រោមទៅវិញ"។

ក្នុងទំនាក់ទំនងដោយផ្ទាល់ជាមួយគ្រូជំនាញ និងការចាប់យកតួនាទីដ៏មានប្រសិទ្ធិភាពជំនួសប្រធានម.ស.ស រួមទាំងការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត កំពុងបំពេញនូវចន្លោះប្រហោងក្នុងការរៀបចំផែនការនៅថ្នាក់មូលដ្ឋាន ប៉ុន្តែពួកគេក៏ត្រូវបានរៀបរាប់ថាខកខានមិនបានស្នើសុំផែនការពីថ្នាក់មូលដ្ឋានក្នុងកាលៈទេសៈខ្លះ ប្រហែលជាមកពីបទពិសោធន៍ ឬកង្វល់ពីមុនលើកង្វះសមត្ថភាពនៅកម្រិតទាំងនោះ។

ទាក់ទងនឹងការបែងចែកថវិកា មន្ទីរអប់រំខេត្តជាភាគីដ៏ចម្បងសម្រាប់ព័ត៌មានលើថវិកា រួមទាំងម.ស.ស។ ទោះជាយ៉ាងណាក៏ដោយ វាជាការច្បាស់ដែលថាមន្ទីរអប់រំខេត្តមិនទទួលបន្ទុកទាំងស្រុងក្នុងដំណើរការផ្ទេរហិរញ្ញវត្ថុទេ។ ការចរចា ការលៃតម្រូវ និងការអនុម័តថវិកាត្រូវ បានធ្វើឡើងដោយនាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៅថ្នាក់ជាតិឯណោះទេ។ មន្ទីរអប់រំខេត្ត ជាទូទៅកំពុងរង់ចាំការជូនដំណឹងពីក្រសួងអប់រំ ហើយបន្ទាប់មកកែតម្រូវផែនការមូលដ្ឋាន តាមការជូនដំណឹង។ នេះនាំឱ្យផែនការពីថ្នាក់ក្រោមទៅលើមានការកែសម្រួលយ៉ាងខ្លាំងប្រសិនបើផែនការទាំងនោះត្រូវបានបង្កើតតាំងពីដំបូង។

ការិយាល័យអប់រំស្រុកមានតួនាទីយ៉ាងសំខាន់ ក្នុងការទម្លាក់ថវិកាទៅកាន់មជ្ឈមណ្ឌលសិក្សាសហគមន៍ ហើយនេះក៏ជះឥទ្ធិពលដល់ការងារ និងកម្រិតនៃការពេញចិត្តក្នុងចំណោមភាគីពាក់ព័ន្ធផងដែរ។ ការិយាល័យអប់រំស្រុកត្រូវបានគេសម្មតថាដើរតួនាទីមួយក្នុងការផ្សារភ្ជាប់មូលនិធិពីមន្ទីរអប់រំខេត្តទៅម.ស.ស ប៉ុន្តែការិយាល័យអប់រំស្រុកខ្លះបានពង្រីកតួនាទីខ្លួនដោយគ្រប់គ្រងមូលនិធិរបស់ម.ស.ស ដើម្បីទិញសម្ភារៈ និងទូទាត់ប្រាក់បៀវត្សអោយគ្រូជំនាញដោយផ្ទាល់ទៅវិញ។ បញ្ហាក្នុងរឿងនេះរួមបញ្ចូលភាពមិនត្រូវគ្នានៃសម្ភារៈទៅនឹងតម្រូវការរបស់ថ្នាក់មូលដ្ឋាន ហើយនិងការកាត់បន្ថយប្រាក់បៀវត្សរបស់គ្រូជំនាញ។

អ្នកផ្តល់បទសម្ភាសន៍ទាំងអស់យល់ស្របថាការទម្លាក់ថវិកាយឺតយ៉ាវ។ វាមានការពន្យាពេលទាំងការផ្តល់ថវិកា និងសម្ភារៈទៅម.ស.ស ហើយប្រាក់បៀវត្សរបស់គ្រូជំនាញក៏ហាក់ជាអាទិភាពចុងក្រោយគេ។ ការផ្តល់សម្ភារៈបង្រៀនបានបន្ថែមភាពមិនសប្បាយចិត្តចំពោះការបង្រៀនដោយសារតែត្រូវផ្អាកខណៈពេលដែលរង់ចាំសម្ភារៈ។ ការបែងចែក និងការទម្លាក់ថវិកាតាមគំរូណាមួយដែលត្រូវបានអនុវត្តក៏ដោយក៏បន្ទុកនៃការរៀបចំឯកសារលិខិតស្នាមហិរញ្ញវត្ថុ (ឧទាហរណ៍ការទូទាត់បង្កាន់ដៃ) នៅតែជាមូលហេតុនៃការពន្យាពេលដ៏ចម្បងមួយដែលត្រូវបានរកឃើញ។
ប្រធានម.ស.សជាច្រើនត្រូវការការគាំទ្រ ទាំងការពង្រឹងសមត្ថភាព និងការលើកទឹកចិត្តក្នុងការចាត់អាទិភាពលើទាំងការរៀបចំផែនការ និងការរៀបចំឯកសារទូទាត់ហិរញ្ញវត្ថុ។

វាជាការសន្និដ្ឋានចុងក្រោយរបស់ពួកយើងដែលថាមានភាពតានតឹងដ៏សំខាន់មួយរវាងវិធីសាស្ត្ររៀបចំផែនការបែបពីក្រោមទៅលើដូចបានចែងក្នុងគោលការណ៍ណែនាំថ្នាក់ជាតិនិងតថភាពជាក់ស្តែងនាំការបែងចែកសម្រាប់ម.ស.សនីមួយៗ។ រូបមន្តថ្នាក់ជាតិមានអត្ថប្រយោជន៍ក្នុងលក្ខខណ្ឌនៃភាព សាមញ្ញ និងតម្លាភាព ប៉ុន្តែជាការអនុវត្តន៍ជាក់ស្តែងពួក យើងមិនបានសង្កេតឃើញរូបមន្តត្រូវបានអនុវត្តតាមឡើយ។ មានការពន្យាពេលសំខាន់ៗ ជាច្រើនក្នុងប្រព័ន្ធសម្រាប់ចំនួនថវិកាដ៏ស្ដួចស្តើងសម្រាប់ម.ស.សនីមួយៗ ដែលបានបង្កជាឧបសគ្គដល់ការផ្តល់សេវាដែលមានគុណភាពកើតឡើងដោយសារការិយាធិបតេយ្យ និងដោយសារសមត្ថភាពមានកម្រិត ហើយដោយការិយាល័យខុសៗគ្នាបង្កើតវិធីសាស្ត្រផ្ទាល់ខ្លួនក្នុងការបែងចែក និងការផ្ទេរហិរញ្ញវត្ថុ។

## VI. អនុសាសន៍

ដោយផ្អែកទៅលើលទ្ធផលនិងសេចក្តីសន្និដ្ឋាននៃការសិក្សាស្រាវជ្រាវនេះ និងក៏ដើម្បីធ្វើឱ្យម.ស.ស ដំណើរការប្រកដដោយប្រសិទ្ធភាពស្របតាមគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីមជ្ឈមណ្ឌលសិក្សាសហគមន៍(ម.ស.ស)យើងផ្តល់ការចាត់វិធានការណ៍ដូចខាងក្រោមៈ

1. ដំណើរការរៀបចំថវិកា និងសកម្មភាពគួរធ្វើតាមគោលការណ៍ណែនាំអំពីម.ស.ស ប៉ុន្តែគួរផ្តោតទៅលើការលុបបំបាត់ឧបសគ្គក្នុងការអនុម័តគោលការណ៍ណែនាំទាំងនេះ ហើយអនុវត្តវានៅកម្រិតថ្នាក់ខេត្ត និងស្រុក។
2. ដំណើរការនានាជុំវិញថវិកាគួរត្រូវបានលៃតម្រូវដើម្បីអនុញ្ញាតឱ្យមានការទម្លាក់ថវិកាមួយជុំនៅដើមឆ្នាំយ៉ាងហោចណាស់សម្រាប់កម្រិតមន្ទីរអប់រំខេត្ត ហើយបើតាមចង់បាន គឺថ្នាក់ម.ស.ស។
3. ជម្រើសគួរត្រូវបានបង្កើនក្នុងការផ្ទេរដោយផ្ទាល់ទៅកាន់ធនាគារ ឬគណនីធនាគារចល័តរបស់ម.ស.សពីនាយកដ្ឋាន ឬមន្ទីរអប់រំខេត្ត។ ដំណើរការគួរត្រូវបានកាត់បន្ថយនូវថ្លៃចំណាយលើការធ្វើដំណើរសម្រាប់ម.ស.ស និងកាត់បន្ថយការផ្លាស់ប្តូរនូវមូលនិធិ និងដំណើរការដែលមានការគាំទ្រយ៉ាងខ្លាំងពីគ្រប់ភាគីទាំងអស់។
4. សវនកម្មឯករាជ្យគួរត្រូវបានប្រើដើម្បីត្រួតពិនិត្យលើប្រព័ន្ធថ្មីនេះ ហើយការិយាល័យ អប់រំស្រុក និងមន្ទីរអប់រំខេត្តគួរចំណាយពេលវេលាលើការធានាគុណភាពជាជាងការផ្ទេរប្រាក់។
5. ការផ្ទេរប្រាក់មិនគួររង់ចាំរហូតដល់ម.ស.ស ឬការិយាល័យអប់រំទាំងអស់បានប្រគល់នូវសំណើ។ វាគួរតែអាចធ្វើទៅរួចសម្រាប់ម.ស.សណាមួយក្នុងការស្នើសុំការទម្លាក់ថវិកា ដើម្បីអនុញ្ញាតឱ្យម.ស.សដែលសកម្មក្នុងការទូទាត់ ឬដកថវិកាដោយមិនចាំបាច់ត្រូវចាំម.ស.ស ឬការិយាល័យអប់រំស្រុកផ្សេងទៀតក្នុងការបញ្ចប់ការរៀបចំឯកសាររបស់ពួកគេទេ។
6. មន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក គួរប្រគល់ការងារឱ្យទៅប្រធានម.ស.ស ហើយដើរតួជាអ្នកពង្រឹងសមត្ថភាពដល់ប្រធានម.ស.សក្នុងការធ្វើផែនការ ការចាត់ចែងថវិកា ការធ្វើរបាយការណ៍ និងការទូទាត់ថវិកា។ ធ្វើបែបនេះនឹងលើកស្ទួយភាពជាម្ចាស់ដល់ម.ស.ស តាមរយៈសហគមន៍ និងធ្វើឱ្យម.ស.សចេះឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាជនមូលដ្ឋានទៀតផង។
7. វេចនាសម្ព័ន្ធនៃការគ្រប់គ្រងបុគ្គលិករបស់ម.ស.សគួរត្រូវបានត្រួតពិនិត្យឡើងវិញ។ កង្វះនៃប្រាក់ឧបត្ថម្ភដល់ប្រធានម.ស.សមានន័យថាតួនាទីនេះអាចមិនត្រូវបានផ្តល់អាទិភាព និងមិនត្រូវបានចូលរួមឱ្យពេញទំហឹង។ ការត្រួតពិនិត្យឡើងវិញគួរត្រូវបានធ្វើឡើង ដើម្បីពិចារណាថាតើតួនាទីមិនពេញម៉ោងអាចទៅរួច ឬអត់ ឬថា តើគួរមានការរៀបចំការគ្រប់គ្រងផ្សេងពីនេះដែរឬទេ ឧទាហរណ៍ ប្រធានម.ស.សដែលធ្វើការពេញម៉ោង ឬបុគ្គលិកក្រៅម៉ោងពីមូលដ្ឋាន និងក្រៅពីវិស័យ អប់រំអាចមានប្រសិទ្ធភាពល្អជាង។

8. ទម្លាប់នៃការទិញបរិក្ខា ឬសម្ភារៈជាច្រើនគួរត្រូវលុបបំបាត់ ហើយគ្រូជំនាញគួរត្រូវបានអនុញ្ញាតឱ្យធ្វើការទិញដោយមានការគ្រប់គ្រង និងត្រួតពិនិត្យត្រឹមត្រូវ ដូចបានចែងក្នុងគោលការណ៍ណែនាំពីមជ្ឈមណ្ឌលសិក្សាសហគមន៍។
9. អគារ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់ម.ស.សគួរត្រូវបានកែលម្អដើម្បីទាក់ទាញសិស្សឱ្យមកសិក្សាក្នុងវគ្គបណ្តុះបណ្តាល និងដើម្បីបង្កើនការប្រើម.ស.សក្នុងសហគមន៍ជាអតិបរមា។
10. ដំណើរទស្សនកិច្ចរវាងម.ស.សគួរត្រូវបានរៀបចំឡើងដើម្បីចែករំលែកនូវបទពិសោធន៍ល្អៗក្នុងការគ្រប់គ្រងម.ស.ស។

## *ឯកសារយោង*


1. *គោលការណ៍ណែនាំពីមជ្ឈមណ្ឌលសិក្សាសហគមន៍ (២០១៣ និង ២០១៤) នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ*

2. *សន្និបាតអប់រំ (២០១៣) ក្រសួងអប់រំ យុវជននិងកីឡា*

3. *កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ (២០០៤) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*


## *ឧបសម្ព័ន្ធ*

1. *កម្រងសំនួរសម្ភាសន៍សម្រាប់ប្រធានមជ្ឈមណ្ឌល*
2. *កម្រងសំនួរសម្ភាសន៍សម្រាប់ការិយាល័យអប់រំស្រុក*
3. *កម្រងសំនួរសម្ភាសន៍សម្រាប់មន្ទីរអប់រំខេត្ត*
4. *កម្រងសំនួរសម្ភាសន៍សម្រាប់រតនាគារ*
5. *កម្រងសំនួរសម្រាប់កិច្ចពិភាក្សាជាមួយគ្រូជំនាញ*